


ជោគជ័យជាមួយគ្នា

For Better Tomorrow

# របាយការណ៍ប្រចាំឆ្នាំ ២០២៤

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី

ANAKUT MICROFINANCE INSTITUTION PLC

អនាគត

ANAKUT

ជោគជ័យជាមួយគ្នា For Better Tomorrow

# មាតិកា

## ក ការវិវត្តអាជីវកម្ម


បេសកកម្ម និង ទស្សនវិស័យ .................................... ៥
តម្លៃស្នូល .............................................................. ៦
រចនាសម្ព័ន្ធគ្រប់គ្រង ..................................................៧
ទិន្នន័យសំខាន់ៗ ...................................................... ៨
ភាគទុនិក .............................................................. ៩
របាយការណ៍ប្រធានក្រុមប្រឹក្សាភិបាល.....................១០
របាយការណ៍របស់លោកអគ្គនាយក ........................ ១២
ក្រុមប្រឹក្សាភិបាល ..................................................១៤
គណៈគ្រប់គ្រង .......................................................១៦
សមិទ្ធផល និងព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ .............២២


## គ របាយការណ៍ហិរញ្ញវត្ថុ


របាយការណ៍ក្រុមប្រឹក្សាភិបាល ..............................៣៣
របាយការណ៍របស់សវនករឯករាជ្យ ........................ ៣៦
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ............................ ៣៩
របាយការណ៍ចំណូលពេញលេញ.............................៤០
របាយការណ៍បម្រែបម្រួលមូលធន...........................៤១
របាយការណ៍លំហូរសាច់ប្រាក់................................ ៤២


## ខ ផលិតផល និងអតិថិជន


ផលិតផល និងអតិថិជន.......................................២៩


## ឃ អាសយដ្ឋានទាក់ទង


ទីស្នាក់ការកណ្តាល និងសាខា...............................៤៥
ដៃគូសហការ ......................................................៤៦
កំណត់សម្គាល់.......................................................៤៧

# ការវិវត្តអាជីវកម្ម

# បេសកកម្មនិងទស្សនវិស័យ

## បេសកកម្ម

ដើម្បីគាំទ្រនិងផ្គត់ផ្គង់ទៅដល់តម្រូវការសេវាហិរញ្ញវត្ថុដែលមានលក្ខណៈយុត្តិធម៌សមហេតុផលនិងមាននិរន្តរភាពដល់សហគ្រាសធុនតូច និងមធ្យម ។



## ទស្សនវិស័យ

ជាគ្រឹះស្ថានហិរញ្ញវត្ថុឈានមុខគេនៅក្នុងប្រទេសកម្ពុជាដែលចូលរួមចំណែកដល់ការបង្កើនកម្រិតជីវភាពរស់នៅដល់សហគមន៍ដែលយើងខ្ញុំបានផ្តល់សេវាកម្មប្រកបទៅដោយក្រមសីលធម៌ និងវិជ្ជាជីវៈ ។



# តម្លៃស្នូល

## ការងារជាក្រុម
## TEAMWORK

យើងធ្វើការដើម្បីឆ្ពោះទៅរកគោលដៅរួមមួយ ដោយផ្អែកលើទំនាក់ទំនងជាចំហ និងភាពស្មោះត្រង់ជាមួយនឹងការបង្ហាញពីការសហការទៅវិញទៅមក។

## បើកចិត្តឲ្យទូលាយ
## OPEN MINDED

យើងមានឆន្ទៈនៅក្នុងការស្តាប់ និងពិចារណារាល់ មតិយោបល់ និងឱកាសក្នុងការធ្វើឲ្យប្រសើរឡើងពីរបៀប នៃការបំពេញការងារ។

## លទ្ធផលសម្រេចជាគោល
## RESULT DRIVE

យើងប្តេជ្ញាធ្វើឲ្យរីកចម្រើន ទាំងអស់គ្នា និងនាំមកនូវ លទ្ធផលល្អបំផុតជាមួយសេវាកម្មដ៏មាន ប្រសិទ្ធភាព សម្រាប់ ភាគីដែលពាក់ព័ន្ធទាំងអស់។

## ការរីកចម្រើនទៅមុខ
## GROWTH

យើង មាន មហិច្ឆតា ដើម្បី ឲ្យ ក្រុម ហ៊ុន មានភាពល្អ ប្រសើររួមផ្សំទាំងដំណើរការ និង សមត្ថភាពបុគ្គលិក។




## ឧត្តមភាព
## EXCELLENCE

យើងកំណត់ការផ្តល់សេវាកម្មជា លក្ខណៈបទដ្ឋានតាមរយៈការធ្វើឲ្យរឹតតែ ប្រសើរឡើង បង្កើនស្នាមញញឹមផ្តល់សេវាកម្មមានលក្ខណៈបត់បែន និងបន្តការធ្វើឲ្យប្រសើរឡើងទៅមុខជានិច្ច។

## ក្រមសីលធម៌
## ETHICAL

យើងធានាឲ្យបាននូវ ភាពមិនលម្អៀងភាពទៀងត្រង់ ការគ្រប់គ្រងប្រកបដោយបទដ្ឋានស្តង់ដារជាមួយ អតិថិជនក្រុមការងារ និងសហគមន៍ជាដើម។

## ភាពស្មោះត្រង់
## HONESTY

យើងបម្រើសេវាកម្មជូន អតិថិជនទាំងអស់ដោយស្មើភាពគ្នា ដោយគ្មានការទាញយកប្រយោជន៍ដើម្បី បង្កើនទំនាក់ទំនងដ៏យូរអង្វែងដែល ពឹងផ្អែកទៅលើការគោរព និងការយោគយល់ទៅវិញទៅមក។

## ភាពជឿទុកចិត្ត
## TRUST WORTHY

យើងព្យាយាមធ្វើសកម្មភាពដែល កសាងនូវការជឿទុកចិត្ត ជាមួយវិនិយោគិនអតិថិជន ដៃគូសហការ និងម្ចាស់ភាគហ៊ុន។ រាល់ព័ត៌មានសម្ងាត់ទាំងឡាយគឺជាការយកចិត្តទុកដាក់ខ្ពស់បំផុតក្នុងការរក្សាទុក។

# រចនាសម្ព័ន្ធគ្រប់គ្រង



# ទិន្នន័យសំខាន់ៗ

## ទ្រព្យសកម្ម




## សមតុល្យឥណទាន



# ភាគទុនិក

រចនាសម្ព័ន្ធរបស់ម្ចាស់ភាគហ៊ុន និងការកាន់កាប់ភាគហ៊ុនចុះបញ្ជីមានដូចខាងក្រោមៈ

| ចំនួនទឹកប្រាក់ជាដុល្លារអាមេរិក | | ២០២៣ | | ២០២៤ | |
|---|---|---|---|---|---|
| ល.រ | ឈ្មោះភាគទុនិក | ដើមទុន | %នៃដើមទុន | ដើមទុន | %នៃដើមទុន |
| ១ | លោកជំទាវ សារុន វិធុរ័ត្ន | ២,១៦០,០០០ | ៧២% | ២,១៦០,០០០ | ៧២% |
| ២ | ឯកឧត្តម តាំង ផុងលី | ៦០០,០០០ | ២០% | ៦០០,០០០ | ២០% |
| ៣ | លោក គៀត វុត្ថា | ១៥០,០០០ | ៥% | ១៥០,០០០ | ៥% |
| ៤ | លោក ឃិន សុផាន | ៩០,០០០ | ៣% | ៩០,០០០ | ៣% |
| | | ៣,០០០,០០០ | ១០០% | ៣,០០០,០០០ | ១០០% |

# របាយការណ៍ប្រធានក្រុមប្រឹក្សាភិបាល



**លោកជំទាវ សារុន វិធុរ័ត្ន**
**សហស្ថាបនិក/ប្រធានក្រុមប្រឹក្សាភិបាល**



**ឯកឧត្តម តាំង ផុងលី**
**សហស្ថាបនិក**

ក្នុងនាមជាភាគទុនិក និងជាក្រុមប្រឹក្សាភិបាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី យើងខ្ញុំមានសេចក្តីសោមនស្សរីករាយសូមធ្វើការបង្ហាញជូនលោកអ្នកនូវរបាយការណ៍ប្រចាំឆ្នាំ២០២៤។ របាយការណ៍នេះគឺបង្ហាញអំពីសមិទ្ធិផលសំខាន់ៗ ក្នុងឆ្នាំ២០២៤ ព្រមទាំងរៀបរាប់អំពីជីវភាពកាន់តែប្រសើរឡើងរបស់អតិថិជនមួយចំនួនបន្ទាប់ពីទទួលបានកម្ចីពីគ្រឹះស្ថានទៅពង្រីកមុខរបររបស់ពួកគាត់។

ដោយសារក្នុងឆ្នាំ២០២៤នេះ សេដ្ឋកិច្ចពិភពលោកបានដក់សល់នូវផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩ ព្រមទាំងបន្តអូសបន្លាយជាមួយនឹង សង្គ្រាមរវាង រុស្ស៊ី-អ៊ុយក្រែន សង្គ្រាមរវាងអ៊ីស្រាអែល-មហាម៉ាស់ អ៊ីរ៉ង់និងថ្មីៗនេះសង្គ្រាមពាណិជ្ជកម្មក៏ចាប់ផ្តើមរវាងសហរដ្ឋអាមេរិក ទល់ជាមួយនឹងប្រទេសជាច្រើនលើសកលលោក ដែលអាចបន្តប៉ះពាល់ដល់ខ្សែច្រវាក់ផ្គត់ផ្គង់សកល បានដាក់សម្ពាធទៅលើអតិផរណា និងការតម្លើងអត្រាការប្រាក់របស់ធនាគារកណ្តាលអាមេរិក កត្តាទាំងនោះធ្វើឲ្យប្រទេសកម្ពុជា ក៏ទទួលរងពីឥទ្ធិពលអវិជ្ជមានជាច្រើនដែរ។ សេដ្ឋកិច្ចប្រទេសកម្ពុជា បានរងនូវផលអវិជ្ជមានទៅលើ វិស័យ ទេសចរណ៍ វិស័យនាំចេញផលិតផលសំលៀកបំពាក់និងស្បែកជើង និងវិស័យសំណង់និងអចលនទ្រព្យ ។ ទោះយ៉ាងណាដោយសារកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាសម្រេចបានក្នុងវិស័យកសិកម្ម និង ធនាគារ ជាមួយការកើនឡើងនៃការនាំចេញផលលិតផលមួយចំនួនដែលជាផលិតផលនៃការធ្វើពិពិធកម្មកន្លងមកនេះ កំណើនត្រឹមប្រមាណអត្រា៥,៥% នៅឆ្នាំ២០២៤ (យោងតាមរបាយការណ៍របស់ធនាគារពិភពលោក “World Bank”) ។

បើទោះជាវិស័យផ្សេងៗទទួលរងនូវផលប៉ះពាល់យ៉ាងណាក៏ដោយ តែវិស័យធនាគារ និង ហិរញ្ញវត្ថុ នៅតែជាកម្លាំង ចលករដ៏សំខាន់ក្នុងការគាំទ្រចូលរួមនិង ជំរុញសក្តានុពលរបស់ខ្លួន ទៅលើវិស័យទាំងនោះ ឲ្យមានការអភិវឌ្ឍន៍ចេរភាពឡើងក្នុង ឆ្នាំ ២០២៥។

## លទ្ធផលឆ្នាំ ២០២៤

ក្នុងរយៈពេល១២ខែកន្លងមកនេះ យើងក៏បានជួបប្រឈមមុខនឹងបញ្ហាដូចជាមានការកើនឡើងបន្តិចបើធៀប នឹងឆ្នាំ២០២៣ នៃកម្ចីមិនដំណើរការ (NPL) ដោយមានការកើនឡើងខ្លះបណ្តាលមកពីកត្តាដូចបានរៀបរាប់ខាងលើ។ ក្នុងឆ្នាំ២០២៤ ទ្រព្យសកម្មសរុបរបស់ គ្រឹះស្ថានបានធ្លាក់ចុះប្រមាណ ២៥,០៨% ពី ៥.០៥៩.៧៤៦ ដុល្លារអាមេរិក មកត្រឹម ៣.៧៩០.៨៧៧ ដុល្លារអាមេរិក បើធៀបទៅនឹងឆ្នាំ២០២៣។ សមតុល្យឥណទានដុលមាន ៣.៤៦១.៥៣៤ ដុល្លារអាមេរិក បានធ្លាក់ចុះ ២៦,១០% ពីឆ្នាំ២០២៣។

## កិច្ចការសង្គម

ដោយការមើលឃើញអំពីសារៈសំខាន់ នៃការផ្តល់ជូនទៅវិញដល់សហគមន៍ និងការទទួលខុសត្រូវមួយនៅក្នុងសង្គមជាពិសេសនោះគឺ ការចូលរួមជាមួយរាជរដ្ឋាភិបាល ហេតុនេះហើយបានជា ឯកឧត្តម តាំង ជុងលី រួមជាមួយនិង លោកជំទាវ សារុន វិធុរត្ន័ ព្រមទាំងក្រុមគ្រួសារ អមដំណើរដោយបុគ្គលិកគ្រប់ជាន់ថ្នាក់ទាំងអស់ តាំងនាមឲ្យស្ថាប័នក៏បានទៅចូលរួមជាមួយសកម្មភាពសង្គមមនុស្សធម៌យ៉ាងទូលំទូលាយជាមួយសមាគមន៍ និងមូលនិធិនានា រួមទាំងទ័យទាន ថវិកាមួយចំនួន និងចង្ហាន់សម្រាប់ប្រគេនជូនទៅដល់ព្រះសង្ឃចំនួន ៣៥០អង្គ ផងដែរ។

## ទិសដៅសម្រាប់ឆ្នាំ២០២៥

នៅក្នុងឆ្នាំ២០២៥នេះផងដែរ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី នឹងបន្តការជ្រើសរើសបុគ្គលិកបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជន និងស្របទៅតាមផែនការពង្រីករបស់ខ្លួន។ យើងនឹងស្វែងរកថវិកាបន្ថែមទៀតដើម្បីគាំទ្រទៅដល់ ប្រតិបត្តិការ បង្កើតផលិតផល និងសេវាកម្មថ្មីៗ ដែលសមស្របនឹងតម្រូវការទីផ្សារ ប៉ុន្តែក៏ផ្តោតទៅលើដំណោះស្រាយ ការគ្រប់គ្រងហានិភ័យទាំងមធ្យោបាយសកម្ម និងការប្រុងប្រយ័ត្នខ្ពស់ជាពិសេសឥណទានមិនដំណើរការ។

## សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមឆ្លៀតយកឱកាសនេះ ថ្លែងអំណរគុណចំពោះ ដៃគូពាក់ព័ន្ធទាំងអស់ រួមទាំងអតិថិជន វិនិយោគិន ធនាគារ និងដៃគូផ្តល់មូលនិធិសម្រាប់ការជឿទុកចិត្ត នឹងកិច្ចសហប្រតិបត្តិការចាប់តាំងពីពេលចាប់ផ្តើមដំបូងរហូតមកទល់បច្ចុប្បន្ន។

យើងខ្ញុំក៏សូមថ្លែងអំណរគុណជូនចំពោះក្រុមប្រឹក្សាភិបាល ដែលបានប្តេជ្ញាចិត្តចំពោះការណែនាំ ពន្យល់ និងចង្អុលបង្ហាញព្រមទាំងគណៈគ្រប់គ្រង និងបុគ្គលិកដ៏ស្មោះត្រង់ ចំពោះការខិតខំប្រឹងប្រែង និងព្យាយាមខ្ពស់ក្នុងការអភិវឌ្ឍ រួមជាមួយអតិថិជន។ ជាទីបញ្ចប់ យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសចំពោះ រាជរដ្ឋាភិបាលកម្ពុជា ធនាគារជាតិនៃកម្ពុជា និងអាជ្ញាធរដែលពាក់ព័ន្ធទាំងអស់ដែលបានគាំទ្រ ការពារ ស្រឡាញ់ និងយកចិត្តទុកដាក់ខ្ពស់ជាប្រចាំចំពោះ ការអភិវឌ្ឍប្រទេសកម្ពុជា។

**លោកជំទាវ សារុន វិធុរ័ត្ន**
សហស្ថាបនិក/ប្រធានក្រុមប្រឹក្សាភិបាល

**ឯកឧត្តម តាំង ជុងលី**
សហស្ថាបនិក

# របាយការណ៍របស់លោកអគ្គនាយក



លោក គៀត វុត្ថា
អគ្គនាយក

## សេចក្តីផ្តើម

យោងទៅតាមរបាយការណ៍ប្រចាំឆ្នាំរបស់ធនាគារពិភពលោក ក្នុងឆ្នាំ២០២៤នេះ សេដ្ឋកិច្ចពិភពលោកបាននៅតែរងផលប៉ះពាល់ធ្ងន់ធ្ងរនៃជំងឺកូវីដ-១៩នៅឡើយ ព្រមទាំងសង្គ្រាមរវាងរុស្ស៊ី-អ៊ុយក្រែន សង្គ្រាមរវាងអ៊ីស្រាអែល-មហាម៉ាស់ អ៊ែរ៉ង់នៅតែបន្ត ព្រមជាមួយនោះសង្គ្រាមពាណិជ្ជកម្មក៏ចាប់ផ្តើម ក្នុងនោះប្រទេសកម្ពុជា មិនអាចគេចផុតបានពីឥទ្ធិពលអវិជ្ជមាន នៃវិបត្តិនេះបានទេ ជាពិសេសវិស័យ ទេសចរណ៍ វិស័យនាំចេញផលិតផលសំលៀកបំពាក់ស្បែកជើង វិស័យសំណង់ និងអចលនទ្រព្យ ព្រមទាំងអតិផរណាផងដែរ។ ទោះជាយ៉ាងណាដោយសារកំណើនសេដ្ឋកិច្ច របស់ប្រទេសកម្ពុជាបានស្តារឡើងវិញបណ្តើរៗ ហើយសម្រេចបានផលល្អក្នុងវិស័យទេសចរណ៍ , កសិកម្ម និង ធនាគារ ជាមួយការកើនឡើងនៃការនាំចេញផលិតផលមួយចំនួនដែលជាផលិតផលនៃការធ្វើពិពិធកម្ម កន្លងមកចំពោះសេដ្ឋកិច្ចកម្ពុជាមាន កំណើនត្រឹមប្រមាណអត្រា៦% នៅឆ្នាំដំណាច់ឆ្នាំ២០២៤ (យោងតាមរបាយការណ៍ប្រចាំឆ្នាំ២០២៤ នៃធនាគារអភិវឌ្ឍន៍អាស៊ី)។

ទោះជាវិស័យផ្សេងៗទទួលរងផលប៉ះពាល់យ៉ាងណាក៏ដោយ តែវិស័យធនាគារ និង ហិរញ្ញវត្ថុ នៅតែជាកម្លាំងចលករដ៏សំខាន់ក្នុងការគាំទ្រ ចូលរួមនិង ជំរុញសក្តានុពលរបស់ខ្លួន ទៅលើវិស័យទាំងនោះឲ្យកាន់តែមាន ការអភិវឌ្ឍចេរភាពឡើងវិញ។ នៅដំណាច់ឆ្នាំ២០២៤នេះ ធនាគារពាណិជ្ជសរុបចំនួន៥៩ ធនាគារឯកទេស៩ គ្រឹះស្ថានហិរញ្ញវត្ថុ សរុបមានចំនួន ៨៩ ។

## លទ្ធផលឆ្នាំ២០២៤

ក្នុងឆ្នាំ២០២៤នេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី បានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើ ការពង្រឹងសមត្ថភាពបុគ្គលិកគ្រប់ផ្នែក ជាពិសេសផ្នែកការគ្រប់គ្រងឥណទាន ដើម្បីពង្រីក និង បានបង្កើតសាខាថ្មីមួយក្នុងឆ្នាំ២០២៤នេះ។ ជាលទ្ធផលជោគជ័យយើងក៏សម្រេចបានក្នុងឆ្នាំ២០២៤ រួមមាន សមតុល្យឥណទានដុលដែលមាន ១៣,៩៣៣.៦៧លានរៀល បានថយចុះ ២៧.១៩% ពីឆ្នាំ២០២៣ ក្នុងនោះចំនួន១៤.៩៩ លានរៀលស្មើនឹង ០.០៧% ក៏ត្រូវបានផ្តល់ទៅលើ វិស័យកសិកម្ម ចំនួន ៩,១៤៣.៧៧ លានរៀល ស្មើនឹង ៤៥.២៩% ផ្តល់លើវិស័យសេវាកម្ម/ពាណិជ្ជកម្ម និងចំនួន ៩,៧៥៩.៣៩ លានរៀល ស្មើនឹង ៤៨.៣៤% ផ្តល់លើវិស័យមុខរបរខ្នាតតូចជាលក្ខណៈគ្រួសារ និងទឹកប្រាក់ ១,២៧០.៤២លានរៀលស្មើនឹង៦.២៩%លើមុខរបរផ្សេងៗ។ ចំនួនសរុបអតិថិជនមាន៨៥១នាក់ បានថយចុះ ៥០.២៩% ពីឆ្នាំ ២០២៣។ ឥណទានមិនដំណើរការមានការកើនឡើងពី ២៦.៩១% ទៅ ៣១.៨២% ក្នុងឆ្នាំ២០២៤។ ទ្រព្យសកម្មសរុបមាន ១៥,២៥៨.២៨ លានរៀល ថយចុះ ២៦.១៨% ធៀបនឹងឆ្នាំ ២០២៣ ។ អនុបាតសោធនភាពមាន ៣៨.៩៧% បានលើសពីកំរិតកំណត់អប្បបរមា របស់ធនាគារជាតិនៃកម្ពុជាដែលមាន ១៥% ប៉ុណ្ណោះ ។

## ទិសដៅសម្រាប់ឆ្នាំ២០២៥

ក្នុងឆ្នាំ២០២៥ និងឆ្នាំបន្តបន្ទាប់យើងមានគំរោងពង្រីកអាជីវកម្ម ដោយបើកសាខាថ្មីមួយទៀតនៅ ខេត្តកណ្តាល នៅក្នុងឆ្នាំ២០២៦ ដើម្បីផ្តល់សេវាឥណទាន ជូនទៅដល់ប្រជាពលរដ្ឋនៅក្បែរនោះ។ នៅឆ្នាំបន្តបន្ទាប់ យើងក៏មាន

គំរោងបើកសាខានៅខេត្តតាកែវ និងខេត្តកំពង់ស្ពឺ ។ ក្នុងការគាំទ្រគំរោងការនេះ យើងត្រូវខំស្វះស្វែងរកប្រភពទុនបន្ថែមទៀត ដើម្បីធានាដល់ភាពរីកចំរើន និងនិរន្តភាពរបស់គ្រឹះស្ថាន។

បច្ចុប្បន្នយើងក៏មាននូវ បច្ចេកវិទ្យាព័ត៌មាន នៅក្នុងការគ្រប់គ្រងទិន្នន័យគណនេយ្យ និង ឥណទានបានយ៉ាងល្អប្រសើរ និងមានភាពងាយស្រួលតភ្ជាប់ពីសាខា ទៅសាខា និង ការិយាល័យកណ្តាល ទៅសាខា ប្រកបដោយសុវត្ថិភាពខ្ពស់។ បុគ្គលិកយើងមានជំនាញខ្ពស់ក្នុងការធ្វើបច្ចុប្បន្នភាព នៅលើរបាយការណ៍ធនាគារជាតិ និង របាយការណ៍ផ្សេងៗ បំពេញតាមតម្រូវការរបស់គ្រឹះស្ថាន។

ចំពោះការបណ្តុះបណ្តាលទៅដល់បុគ្គលិកវិញ បុគ្គលិកភាគច្រើនសុទ្ធតែមានចំណេះដឹងសមស្របនឹងតម្រូវការទាំងបទពិសោធន៍ការងារ និងជំនាញគ្រប់គ្រាន់ដែលមានកំរិតវប្បធម៌ចាប់ពីបរិញ្ញាប័ត្ររងរហូតទៅដល់បរិញ្ញាប័ត្រជាន់ខ្ពស់។ ក្នុងនោះដែរយើងក៏បានធ្វើការបណ្តុះបណ្តាលបុគ្គលិកក្នុងមួយឆ្នាំយ៉ាងតិច២ដង និងបញ្ជូនទៅរៀនសូត្របន្ថែមពីស្ថាប័នដទៃទៀត ដើម្បីអោយធនធានមនុស្សរបស់យើងមានសមត្ថភាពខ្ពស់នៅក្នុងការបំរើការងារ ជាពិសេសយើងក៏មានបដិភាគថវិកាក្នុងការចូលរួមជាមួយសមាគមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងការបណ្តុះបណ្តាលបុគ្គលិកនេះផងដែរ។

## ចក្ខុវិស័យ

ចំពោះចក្ខុវិស័យសំរាប់ឆ្នាំ២០២៥ កំណើនសេដ្ឋកិច្ចប្រទេសកម្ពុជា ត្រូវបានព្យាករណ៍ របស់ធនាគារពិភពលោក "World Bank" ថានឹងត្រូវបានងើបឡើងវិញជាមួយនឹងអត្រាកំណើនចន្លោះពី ៥.៨% ទៅ ៦.១% (យោងតាមរបាយការណ៍របស់ធនាគារពិភពលោក "World Bank") នៅឆ្នាំ២០២៥នេះ ហើយរក្សាបាននៅសក្តានុពលពីវិស័យគន្លឹះទាំងបួនដូចឆ្នាំ២០២៤ដដែល បើទោះជាយ៉ាងណាក៏សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានរងផលប៉ះពាល់ ស្ទើរគ្រប់វិស័យដោយសារអូសបន្លាយនៃជំងឺកូវីដ១៩ សង្គ្រាមរវាងរុស្ស៊ី-អ៊ុយក្រែន និងសង្គ្រាមរវាងអ៊ីស្រាអែល-មហាម៉ាស់ អ៊ែរ៉ង់ ។ ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី យើងនឹងមានភាពប្រុងប្រយ័ត្នយ៉ាងខ្ពស់នូវក្នុងការរក្សា និងបញ្ចេញឥណទានថ្មីឲ្យបានល្អប្រសើរជាងមុន ទៅតាមរយៈយន្តការគ្រប់គ្រងផ្ទៃក្នុង និង គ្រប់គ្រងហានិភ័យ ឲ្យបានត្រឹមត្រូវ រួមទាំងការអនុវត្តទៅតាមបទបញ្ញត្តិនានា របស់ធនាគារជាតិនៃកម្ពុជាយ៉ាងម៉ឺងម៉ាត់ ។

## សេចក្តីថ្លែងអំណរគុណ

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះក្រុមប្រឹក្សាភិបាល ដែលបានផ្តល់អនុសាសន៍ណែនាំនិងគាំទ្រយ៉ាងជ្រាលជ្រៅជូនទៅដល់គណៈគ្រប់គ្រង ក៏ដូចជាបុគ្គលិកទាំងអស់របស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី ។ ខ្ញុំសូមថ្លែងអរគុណ និង កោតសរសើរផងដែរដល់បុគ្គលិកទាំងអស់ក្នុងការខិតខំប្រឹងប្រែង ភាពឧស្សាហ៍ព្យាយាម ភាពស្មោះត្រង់ និងការប្តេជ្ញាចិត្តយ៉ាងខ្ពស់របស់បុគ្គលិកក្នុងការបំពេញការងារកន្លងមក។ ខ្ញុំសូមធ្វើការថ្លែងអរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះអតិថិជនដែលបានគាំទ្រ និង មានការទំនុកចិត្តមកលើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី របស់យើងខ្ញុំ ទាំងបច្ចុប្បន្ន និង ទៅថ្ងៃអនាគត។

ជាទីបញ្ចប់នេះ យើងខ្ញុំក៏សូមសំដែងនូវអំណរគុណដ៏ជ្រាលជ្រៅបំផុតជូនចំពោះ គណៈគ្រប់គ្រងជាន់ខ្ពស់របស់ធនាគារជាតិនៃកម្ពុជា ដែលតែងតែបន្តជួយគាំទ្រនិងផ្តល់អនុសាសន៍ល្អៗដល់គ្រឹះស្ថានយើងខ្ញុំ ។



**លោក គៀត វុត្ថា**
**អគ្គនាយក**

# ក្រុមប្រឹក្សាភិបាល



## លោកជំទាវ សារុន វិធុរ័ត្ន
## សហស្ថាបនិក/ប្រធានក្រុមប្រឹក្សាភិបាល

លោកជំទាវ សារុន វិធុរ័ត្ន គឺជាសហស្ថាបនិក និងជាប្រធានក្រុមប្រឹក្សាភិបាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី ចាប់តាំងពីខែមិថុនា ឆ្នាំ២០១៦។

លោកជំទាវបានទៅរស់នៅប្រទេសបារាំងចាប់តាំងពីកុមារភាពមក ហើយលោកជំទាវក៏ទទួលបានបរិញ្ញាបត្រផ្នែកទីផ្សារនៅក្នុងវិស័យធនាគារពីសាកលវិទ្យាល័យ Paris Descartes ក្នុងឆ្នាំ២០០៧ នៅទីក្រុងប៉ារីស ប្រទេសបារាំង។ លោកជំទាវមានបទពិសោធន៍ជាង១០ឆ្នាំ ក្នុងវិស័យធនាគារក្នុងប្រទេស និងក្រៅប្រទេសក្នុងតួនាទីជាច្រើន។ លោកជំទាវក៏បានចាប់ផ្តើមនូវការងារដំបូងរបស់គាត់ក្នុងធនាគារ BNP នៅទីក្រុងប៉ារីស ជាមន្ត្រីហាត់ការ។ នៅឆ្នាំ២០០៨ លោកជំទាវបានត្រលប់មករស់នៅប្រទេសកម្ពុជាវិញហើយលោកជំទាវបានចាប់ផ្តើមការងារដំបូងនៅក្នុងធនាគារ វឌ្ឍនៈ ដែលជាធនាគារស្តង់ដាមួយនៅក្នុងប្រទេសកម្ពុជា ជាមន្ត្រីអភិវឌ្ឍន៍ពាណិជ្ជកម្ម ហើយបន្ទាប់មកត្រូវបានដំឡើងតួនាទីទៅជា មន្ត្រីជាន់ខ្ពស់ ផ្នែកធនធានមនុស្ស និងបណ្តុះបណ្តាល។

លោកជំទាវបានធ្វើការបណ្តាក់ទុនជាច្រើនក្នុងវិស័យពាណិជ្ជកម្មនៅ ប្រទេសកម្ពុជាដូចជា ផ្នែកសុខាភិបាល រោងម៉ាស៊ីនកិនស្រូវ និងកសិកម្មផងដែរ។ លោកជំទាវអាចនិយាយ ស្តាប់ និងសរសេរ ភាសាខ្មែរ បារាំង និងអង់គ្លេសបានយ៉ាងល្អ។



## ឯកឧត្តម តាំង ផុងលី
## សហស្ថាបនិក

ឯកឧត្តម តាំង ផុងលី គឺជាសហស្ថាបនិក នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី ចាប់តាំងពីខែមិថុនា ឆ្នាំ២០១៦។

ឯកឧត្តមបាន បញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកទីផ្សារពី មហាវិទ្យាល័យអន្តរជាតិ KBU ដោយសហការជាមួយសាកលវិទ្យាល័យ Anglia Ruskin ចក្រភពអង់គ្លេស។ នៅក្នុងឆ្នាំ២០១២ ឯកឧត្តមទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង។ នៅក្នុងឆ្នាំ២០២០ ឯកឧត្តមបានបន្តការសិក្សាថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យអន្តរជាតិអឺរ៉ុប នៅប្រទេសបារាំង ផ្នែកវិទ្យាសាស្រ្តនយោបាយ និងបានបញ្ចប់ការសិក្សាក្នុងឆ្នាំ២០២២។

ឯកឧត្តមបានបម្រើការជាប្រធានផ្នែកនៅ នាយកដ្ឋានប្រតិបត្តិការធនាគារជាតិ នៃកម្ពុជា ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៦។ ចាប់តាំងពីឆ្នាំ២០១៦ រហូតមកដល់បច្ចុប្បន្ន ឯកឧត្តមបានបម្រើការជា ទីប្រឹក្សាជាន់ខ្ពស់ និងជាជំនួយការ អគ្គនាយក ក្រុមហ៊ុន សុខ កែវ អ៊ីមផត អ៊ិចផត ខូអិលធីឌី ដែលជា សម្ព័ន្ធក្រុមហ៊ុន Sok Keo Rice Mill and Home City Hotel & Apartment ។ ក្រៅពីនេះ ឯកឧត្តមគឺជា ភាគទុនិក របស់ក្រុមហ៊ុន អនាគត ជីនិត រុងរឿង ខូអិលធីឌី ផងដែរ។

# ក្រុមប្រឹក្សាភិបាល



## លោកស្រី ហេង បូធីតា
## អភិបាលឯករាជ្យ

លោកស្រី ហេង បូធីតា គឺជាអភិបាលឯករាជ្យ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី ចាប់តាំងពី ខែមិថុនា ឆ្នាំ ២០១៦។ លោកស្រី បូធីតា មានបទពិសោធន៍ខាងផ្នែកសវនកម្មជាច្រើនឆ្នាំ។

លោកស្រីបានធ្វើការងារជាសវនកម្ម លើការអនុលោមតាមច្បាប់នៅ ក្រសួងនានាសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ និងបានតែងតាំងជា អ្នកសម្របសម្រួលស្តង់ដារអន្តរជាតិ នៃស្ថាប័នសវនកម្មជាន់ខ្ពស់។ នៅក្នុងឆ្នាំ២០០៦ រហូតដល់បច្ចុប្បន្ន លោកស្រី បានបម្រើការងារនៅ អង្គភាពអាជ្ញាធរសវនកម្មជាតិ តួនាទីជា ប្រធានការិយាល័យ។

លោកស្រី បូធីតា បានបញ្ចប់បរិញ្ញាបត្រ ផ្នែកហិរញ្ញវត្ថុ និងធនាគារនៅ សាកលវិទ្យាល័យជាតិគ្រប់គ្រង និងបានបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកហិរញ្ញវត្ថុនៅសាកលវិទ្យាល័យបញ្ញាសាស្ត្រ នៃកម្ពុជា។ ក្រៅពីការសិក្សានៅសាកលវិទ្យាល័យ លោកស្រីបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនទៀត ដែលទាក់ទងនឹងផ្នែកសវនកម្ម និងចំណេះដឹងទូទៅផ្នែក ភាសាអង់គ្លេស ផងដែរ។



## លោក អ៊ឹត វិធូរ
## អភិបាលឯករាជ្យ

លោក អ៊ឹត វិធូរ គឺជាអភិបាលឯករាជ្យ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី ចាប់តាំងពី ខែមិថុនា ឆ្នាំ ២០១៦។លោកបានបញ្ចប់ការសិក្សាថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ចំនួនពីរគឺ ផ្នែកគ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិ ពីវិទ្យាស្ថានបច្ចេកវិទ្យា អាស៊ី (AIT) ប្រទេសថៃ និងផ្នែកគ្រប់គ្រងធនធានមនុស្ស ពីមជ្ឈមណ្ឌលផ្នែកគ្រប់គ្រង បារាំងវៀតណាម (CFVG)។

លោកបានទទួល សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងសហគ្រាសពី សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគណនេយ្យ ពីសាកលវិទ្យាល័យន័រតុន។

លោកបានចាប់ផ្តើមអាជីពក្នុងការគ្រប់គ្រង ធនធានមនុស្ស អស់រយៈពេលជិត ១៥ឆ្នាំ មកហើយដូចជា ប្រធានគ្រប់គ្រងបុគ្គលិក អ្នកគ្រប់គ្រងសេវាកម្ម ចែករំលែកធនធានមនុស្ស និងជាប្រធាន ធនធានមនុស្សនៅក្នុង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ធនាគារ វឌ្ឍនៈ ធនាគារអេអិនហ្សិត រ៉ូយាល់ និងធនាគារ ហុងលីអុង និងក្រុមហ៊ុនធានារ៉ាប់រង អាយុជីវិត អន្តរជាតិ មេនូឡាយហ្វ៍ ខេមបូឌា និង អេ អាយ អេ ខេមបូឌា។ មុខតំណែងចុងក្រោយរបស់លោកគឺជា នាយកធនធានមនុស្ស នៅ អេ អាយ អេ ខេមបូឌា ឡាយហ្វ៍អ៊ិនសួរេន ភីអិលស៊ី។ បច្ចុប្បន្ននេះលោកគឺជាស្ថាបនិក និងជានាយកគ្រប់គ្រងក្រុមហ៊ុនប្រឹក្សាយោបល់ធនធានមនុស្ស ដែលមានឈ្មោះថា Unity Consult។

# គណៈគ្រប់គ្រង



## លោក គៀត វុត្ថា
## អគ្គនាយក

លោក គៀត វុត្ថា គឺជាអគ្គនាយក នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី។ នៅឆ្នាំ២០០៨ លោកបានបញ្ចប់ថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងពាណិជ្ជកម្មហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅក្នុងឆ្នាំ២០០៨ ដដែលនោះ លោកបានបញ្ចប់ថ្នាក់ បរិញ្ញាបត្រភាសាអង់គ្លេស ផ្នែកទំនាក់ទំនងពាណិជ្ជកម្ម នៅសាកលវិទ្យាល័យន័រតុន។ នៅឆ្នាំ២០០៣ លោកបាន បញ្ចប់ថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ច ជំនាញហិរញ្ញវត្ថុ និងធនាគារ នៅសាកលវិទ្យាល័យន័រតុន។ មុនចូលបម្រើការងារនៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី លោកមានបទពិសោធន៍លើវិស័យធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាច្រើនឆ្នាំ។ លោកធ្លាប់បម្រើការនៅ ធនាគារ អេស៊ីលីដា ជាមន្ត្រីត្រួតពិនិត្យថវិកា បន្ទាប់មកលោកបានផ្លាស់ប្តូរមក គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ តួនាទីជា ប្រធានគ្រប់គ្រងគណនេយ្យ។ នៅឆ្នាំ២០១៣ និងឆ្នាំ២០១៤ លោកបានបម្រើការងារនៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លី ហួរ ភីអិលស៊ី ជាគណៈគ្រប់គ្រងបណ្តុះបណ្តាល និងលី ហួរ លីស៊ីង ភីអិលស៊ី ជានាយកប្រតិបត្តិ។ មុននឹងលោកចូលបម្រើការងារនៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី លោកបានបម្រើការងារនៅ ធនាគារហុងលីអុង តួនាទីជា ប្រធានហិរញ្ញវត្ថុ។



## លោក សែន ចេត្តនា
## នាយក នាយកដ្ឋានហិរញ្ញវត្ថុ

លោក សែន ចេត្តនា បច្ចុប្បន្នគឺជា នាយក នាយកដ្ឋានហិរញ្ញវត្ថុ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី។ នៅឆ្នាំ២០០៧ លោកបានទទួលបរិញ្ញាបត្រផ្នែកធនាគារ និងហិរញ្ញវត្ថុពី សាកលវិទ្យាល័យបៀលប្រាយ។ បន្ទាប់មក នៅក្នុងឆ្នាំ២០១១ លោកបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកធនាគារ និងហិរញ្ញវត្ថុពីសាកលវិទ្យាល័យ បៀលប្រាយ និងបានចូលរួមវគ្គហ្វឹកហ្វឺនខ្លីៗ ផ្នែកគណនេយ្យ និងហិរញ្ញវត្ថុជាច្រើនទៀតមុនចូលបម្រើការងារនៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី។ លោក ចេត្តនា មានបទពិសោធន៍ច្រើនជាង ២០ឆ្នាំ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារ។ លោកធ្លាប់ជា នាយក នាយកដ្ឋានហិរញ្ញវត្ថុ នៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សីលានិធិ ១០ឆ្នាំ ធ្លាប់ជា ប្រធាននាយកដ្ឋាន ផ្នែកគណនេយ្យនៅ ធនាគារ ភ្នំពេញពាណិជ្ជ រយៈពេល ៤ឆ្នាំ និងជាប្រធាន នាយកដ្ឋាន ផ្នែកគណនេយ្យនៅ ធនាគារឯកទេស ខេម ខាប់ភីថល រយៈពេល ១ឆ្នាំ ។

# គណៈគ្រប់គ្រង



## លោក សុខ សុវណ្ណមុន្នី
## នាយក នាយកដ្ឋានឥណទាន

លោក សុខ សុវណ្ណមុន្នី បច្ចុប្បន្នជា នាយក នាយកដ្ឋានឥណទាន នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលសុី។ លោកកើតនៅឆ្នាំ១៩៨០ លោកបានចូលបម្រើការងារជាមួយនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលសុី នៅខែឧសភា ឆ្នាំ២០១៧។ នៅឆ្នាំ២០០៤ និងឆ្នាំ២០០៨ លោកបានបញ្ចប់បរិញ្ញាបត្រ ផ្នែកប្រព័ន្ធគ្រប់គ្រងព័ត៌មាន និងបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង។ មុនចូលបម្រើការងារនៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលសុី លោកធ្លាប់ បម្រើការងារនៅធនាគារ អេសុីលីដា ជាមន្ត្រីឥណទាន ខ្នាតតូច បន្ទាប់មកលោកត្រូវបាន ឡើងតួនាទីជា មន្ត្រីឥណទានខ្នាតមធ្យម តួនាទីចុងក្រោយនៅ ធនាគារ អេសុីលីដា របស់លោកគឺជា អនុប្រធានឥណទាន ចាប់ពីឆ្នាំ២០០៤ រហូតដល់ឆ្នាំ២០១៥។ នៅក្នុងឆ្នាំ ២០១៥ លោកបានបម្រើការងារនៅប្រតិបត្តិការឥណទានជា នាយក នាយកដ្ឋានធនធានមនុស្ស។



## លោក ឡុង ចាន់វណ្ណៈ
## ប្រធានសវនកម្មផ្ទៃក្នុង

លោកឡុង ចាន់វណ្ណៈ កើតនៅឆ្នាំ ១៩៨៥ បានចូលបម្រើការងារជាមួយនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលសុី នៅខែវិច្ឆិកាឆ្នាំ ២០១៨ ជាប្រធានសវនកម្មផ្ទៃក្នុង។ លោកមានបទពិសោធន៍ការងារជាមួយធនាគារនិងមីក្រូហិរញ្ញវត្ថុអស់រយៈពេលជាង ១៣ឆ្នាំមកហើយ។ មុនពេលចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលសុី លោកចាន់វណ្ណៈក៏បានធ្វើជាប្រធានផ្នែកសវនកម្មផ្ទៃក្នុងនៅក្នុងធនាគារឯកទេសអុីអន(កម្ពុជា)ភីអិលសុី។ លោកក៏ធ្លាប់បានចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្រេឌីតភីអិលសុីផងដែរ ដោយឆ្លងកាត់នូវតួនាទីជាច្រើនមានដូចជាភ្នាក់ងារប្រាក់សន្សំ មន្ត្រីឥណទាននិងប្រាក់សន្សំ អ្នកសម្របសម្រួល Kiva និងចុងក្រោយជាសវនករផ្ទៃក្នុង។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ ពី វិទ្យាស្ថាន ហិរញ្ញវត្ថុ និង គណនេយ្យ (IFA) នៅក្នុងឆ្នាំ២០២៣។ លោកក៏ទទួលបានសញ្ញាបត្របរិញ្ញាបត្រពីសាកលវិទ្យាល័យន័រតុនផ្នែកគ្រប់គ្រងអាជីវកម្មជំនាញឯកទេសគណនេយ្យក្នុងឆ្នាំ ២០០៩ និងបរិញ្ញាប័ត្ររងពីមជ្ឈមណ្ឌល Banana នៅក្នុងផ្នែកគ្រប់គ្រងធុរកិច្ចជំនាញគណនេយ្យនៅឆ្នាំ ២០០៦ លោកចាន់វណ្ណៈក៏បានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើននៅក្នុងប្រទេសកម្ពុជាដែលទាក់ទងទៅនឹងសវនកម្ម, ហិរញ្ញវត្ថុ និងពន្ធដារផងដែរ។

# គណៈគ្រប់គ្រង



## លោក ជា សុខលីម
## ប្រធានផ្នែកព័ត៌មានវិទ្យា

លោក ជា សុខលីម កើតនៅឆ្នាំ១៩៨៧។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកគ្រប់គ្រងព័ត៌មានវិទ្យា នៅក្នុងវិទ្យាស្ថានស៊ីតិក។ លោកមានបទពិសោធន៍ច្រើនជាង ១១ឆ្នាំ ក្នុងកិច្ចការងារផ្នែកព័ត៌មានវិទ្យា។ នៅក្នុងឆ្នាំ២០០៩ រហូតដល់ឆ្នាំ២០១៤ លោកបានបម្រើការងារនៅក្នុងក្រុមហ៊ុនផ្តត់ផ្គង់សេវាកម្មប្រព័ន្ធព័ត៌មានវិទ្យាដ៏ធំមួយនៅក្នុងស្រុក ក្នុងតួនាទីជា វិស្វកម្មម៉ាស៊ីនមេនិងការផ្ទុក។ នៅឆ្នាំ២០១៤ ដល់ឆ្នាំ២០២២ លោកបានផ្លាស់ប្តូរកន្លែងការងារទៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រសិទ្ធភាព ហ្វាយនែនភីអិលស៊ី ក្នុងតួនាទីជា ប្រធានផ្នែកព័ត៌មានវិទ្យា។ នៅក្នុងខែសីហា ឆ្នាំ២០២៣ លោកបានផ្លាស់ប្តូរទីកន្លែងការងារមកបម្រើការងារជាមួយនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី ក្នុងតួនាទីជាប្រធានផ្នែកព័ត៌មានវិទ្យា។



## អ្នកស្រី វ៉ាត ស្រីពៅ
## ប្រធានធនធានមនុស្ស និងរដ្ឋបាល

អ្នកស្រី វ៉ាត ស្រីពៅ កើតនៅឆ្នាំ១៩៨៨ ជាប្រធានធនធានមនុស្ស និងរដ្ឋបាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី។ អ្នកស្រីក៏បានចូលមកបម្រើការងារជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអនាគត ភីអិលស៊ី នៅខែធ្នូ ឆ្នាំ២០២១។ អ្នកស្រីបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកធនាគារ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យវេស្ទើន។ មុនពេលអ្នកស្រីចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី អ្នកស្រីក៏ធ្លាប់បានបម្រើការងារជា មន្ត្រីជាន់ខ្ពស់ផ្នែកបណ្តុះបណ្តាល និងជ្រើសរើសបុគ្គលិក នៃគ្រឹះស្ថាន សំរឹទ្ធិស័ក មីក្រូហិរញ្ញវត្ថុ ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២១ និងជាមន្ត្រីបណ្តុះបណ្តាលនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨។ ក្រៅពីការសិក្សា នៅសាកលវិទ្យាល័យ អ្នកស្រីបានចូលរួមវគ្គបណ្តុះបណ្តាល ជាច្រើនទៀត ដែលទាក់ទងការបណ្តុះបណ្តាល និងផ្នែកទំនាក់ទំនង។

# គណៈគ្រប់គ្រង



## អ្នកស្រី សៅ រ៉ាឌី
## ប្រធានគណនេយ្យ

អ្នកស្រី សៅ រ៉ាឌី ជាប្រធានគណនេយ្យ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី ។

អ្នកស្រីកើតនៅឆ្នាំ១៩៨៥ អ្នកស្រីបានចាប់ផ្តើមបម្រើការងារជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី នៅខែកក្កដា ឆ្នាំ២០១៦។ អ្នកស្រីបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកគណនេយ្យ នៅសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ។ មុនពេលអ្នកស្រីចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី អ្នកស្រីធ្លាប់បម្រើការងារ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីធីត អស់រយៈពេល ៦ឆ្នាំពីឆ្នាំ ២០០៨ ដល់ចុងឆ្នាំ ២០១៤ តួនាទីចុងក្រោយជាប្រធានគណនេយ្យ។ ក្រៅពីការសិក្សានៅសាកលវិទ្យាល័យ អ្នកស្រីក៏បានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនទៀត ទៅលើផ្នែកគណនេយ្យ ។



## លោក ជុំ រិទ្ធី
## ប្រធានគាំទ្រសាខា

លោក ជុំ រិទ្ធី កើតនៅឆ្នាំ ១៩៧៩។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ ទៅលើផ្នែកគ្រប់គ្រង នៅវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ។ លោកមានបទពិសោធន៍១៦ឆ្នាំក្នុងកិច្ចការឥណទាន។ នៅក្នុងខែ កញ្ញា ឆ្នាំ ២០០៤ ដល់ខែ ឧសភា ឆ្នាំ ២០០៨ លោកបានចូលបម្រើការនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ក្នុងតួនាទីជា មន្ត្រីឥណទាន នឹងបានដំឡើងតួនាទីជាប្រធានសាខានៅខែ មិថុនា ឆ្នាំ ២០០៨ រហូតដល់ឆ្នាំ ២០១៤។ នៅឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៨ លោកបានផ្លាស់ប្តូរកន្លែងការងារទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លី ហួរ ក្នុងតួនាទីជាប្រធានសាខា ។ នៅក្នុងខែ សីហា ឆ្នាំ ២០២១ លោកបានចូលមកបម្រើការងារជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី ក្នុងតួនាទីជា មន្ត្រីវាយតំលៃឥណទានជាន់ខ្ពស់ ហើយនៅខែ សីហា ឆ្នាំ ២០២២ បានឡើងតំណែងជាប្រធានគាំទ្រសាខា។

# គណៈគ្រប់គ្រង



## លោក សុខ វណ្ណសុជា
## ប្រធានគ្រប់គ្រងឥណទាន

លោក សុខ វណ្ណសុជា កើតនៅឆ្នាំ១៩៨០។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកសេដ្ឋកិច្ចអភិវឌ្ឍន៍ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។ លោកមានបទពិសោធន៍ច្រើនជាង ១៣ឆ្នាំ ក្នុងកិច្ចការងារឥណទាន។ នៅក្នុងឆ្នាំ២០០៣ រហូតដល់ឆ្នាំ ២០១៦ លោកបានបម្រើការងារនៅក្នុង ធនាគារ អេស៊ីលីដា ភីអិលស៊ី ក្នុងតួនាទីជា មន្រ្តីឥណទានខ្នាតតូចបំផុត ខ្នាតតូច ខ្នាតមធ្យម ភ្នាក់ងារឥណទានជាន់ខ្ពស់ និងបានដំឡើងថ្នាក់ជា អនុប្រធានភ្នាក់ងារឥណទានប្រចាំសាខា។ នៅឆ្នាំ២០១៦ ដល់ឆ្នាំ២០១៧ លោកបានផ្លាស់ប្តូរកន្លែងការងារទៅ លី ហួរ លីស៊ីង ភីអិលស៊ី ក្នុងតួនាទីជា ប្រធានផ្នែកហានិភ័យឥណទាន។ នៅក្នុងខែមីនា ឆ្នាំ២០២៣ លោកបានផ្លាស់ប្តូរទីកន្លែងការងារ មកបម្រើការងារជាមួយនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី ក្នុងតួនាទីជា ប្រធានគ្រប់គ្រងឥណទាន។


គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី
ANAKUT MICROFINANCE INSTITUTION PLC
គ្រឹះស្ថានឯកជន

# សមិទ្ធផល និងព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ

## របាយការណ៍បណ្តុះបណ្តាល ប្រចាំឆ្នាំ២០២៤ ៖

របាយការណ៍បណ្តុះបណ្តាលនេះ បានរៀបចំឡើងដើម្បី ហ្វឹកហ្វឺនពីគោលការណ៍ និងនីតិវិធីដល់បុគ្គលិកថ្មី សិក្ខាសាលា និងវគ្គសិក្សា ខ្លីៗ។ល។ គ្រប់និយោជិតទាំងអស់ត្រូវចូលរួមវគ្គសិក្សា តាមការចាត់ចែងរបស់នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាលសហការជាមួយនាយកដ្ឋានពាក់ព័ន្ធរួម។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី រៀបចំវគ្គបណ្តុះបណ្តាល បុគ្គលិក គោលបំណងពង្រឹងសមត្ថភាព ចាប់តាំងពីថ្ងៃដែលគេចូលធ្វើការដំបូងជាមួយគ្រឹះស្ថាន ។

## សកម្មភាពហ្វឹកហ្វឺនខាងក្នុង ឆ្នាំ២០២៤ មានដូចជា៖

**នៅថ្ងៃសុក្រ ទី១៩ ខែមករា ឆ្នាំ២០២៤** បានរៀបចំវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសសម្រាប់ គណៈគ្រប់គ្រងតាមសាខា រយៈពេលកន្លះថ្ងៃ (១ព្រឹក)។

**ប្រធានបទ៖**

- រំលឹកពីផលិតផលឥណទានរបស់ស្ថាប័ន
- ចំនួនបុគ្គលិកស្ថិតក្នុងសាខា
- មុខងាររបស់ថ្នាក់គ្រប់គ្រង និង
- សំណួរនិងចម្លើយ





**នៅថ្ងៃសៅរ៍ ទី២០ ដល់ថ្ងៃអាទិត្យ ទី២១ ខែមករា ឆ្នាំ២០២៤** បានរៀបចំវគ្គបណ្តុះបណ្តាលបុគ្គលិកចូលថ្មី និងបុគ្គលិកផ្នែកពាក់ព័ន្ធឥណទានទាំងអស់ រយៈពេល១ថ្ងៃកន្លះ។

**ប្រធានបទ៖**

- បណ្តុះផ្នត់គំនិត ឆន្ទះបុគ្គលិកថ្មី និងបុគ្គលិកចាស់
- បទបញ្ជាផ្ទៃក្នុង និងគោលនយោបាយធនធានមនុស្ស
- នីតិវិធី និងការប្រើប្រាស់ទម្រង់ឯកសារឥណទាន
- រំលឹកពី ប្រវត្តិ ទស្សនៈវិស័យ បេសកម្មរបស់ស្ថាប័ន និង
- រំលឹកគោលការណ៍ឥណទាន





# សមិទ្ធផល និងព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ(បន្ត)

## សកម្មភាពហ្វឹកហ្វឺនខាងក្នុង ឆ្នាំ២០២៤ (បន្ត)

- **នៅថ្ងៃសៅរ៍ ទី១៥ ខែមិថុនា ឆ្នាំ២០២៤** បានរៀបចំបណ្តុះបណ្តាលសម្រាប់បុគ្គលិកការិយាល័យកណ្តាល និងបុគ្គលិកសាខាទាំងអស់ រយៈពេល២ថ្ងៃ។

**ប្រធានបទ៖**

- ការណែនាំពីវិធានការពិន័យលើភាពធ្វេសប្រហែស (លេខ អ.ន.គ០០៤៤/២០២៤)
- រំលឹកបទវិន័យផ្សេងៗក្នុងស្ថាប័ន និងគន្លឹះក្លាយជាបុគ្គលិកល្អ
- នីតិវិធីក្នុងការបំពេញឯកសារ និង
- រំលឹកគោលការណ៍ឥណទាន









# សមិទ្ធផល និងព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ(បន្ត)

## របាយការណ៍បណ្តុះបណ្តាល ប្រចាំឆ្នាំ២០២៤ (បន្ត)

- **នៅថ្ងៃសៅរ៍ ទី២៨ ខែធ្នូ ឆ្នាំ២០២៤** បានរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់ បុគ្គលិកការិយាល័យកណ្តាល និងបុគ្គលិកសាខាទាំងអស់។

**ប្រធានបទ៖**

- វិធីសាស្ត្រធ្វើការងារដើម្បីក្លាយជាបុគ្គលិកឆ្នើម
- រំលឹកបទវិន័យផ្សេងៗក្នុងស្ថាប័ន/ក្រុមហ៊ុន
- ការបណ្តុះវិន័យឥណទាន និង
- រំលឹកគោលការណ៍ និងនីតិវិធីឥណទាន









# សមិទ្ធផល និងព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ(បន្ត)

## សកម្មភាពហ្វឹកហ្វឺន និងសិក្ខាសាលាខាងក្រៅ ឆ្នាំ២០២៤ មានដូចជា ៖

- **នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤** បានចាត់ចែងបុគ្គលិកផ្នែកឥណទានឲ្យចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការសិក្សាពង្រឹងសមត្ថភាពពាក់ព័ន្ធការផ្តល់ឥណទានប្រកបដោយការទទួលខុសត្រូវ (Certification in responsible lending) ជាមួយសមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា។
- **នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤** បានចាត់ចែងបុគ្គលិកឲ្យចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ចំណាត់ថ្នាក់ហានិភ័យ ឥណទាន និងសំវិធានធនលើអ៊ីមភែរមិន របស់ធនាគារជាតិ នៃកម្ពុជា។
- **នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤** បានចាត់ចែងបុគ្គលិកឲ្យចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការប្រើប្រាស់សេវាធនាគារឌីជីថល និងបច្ចេកវិទ្យាថ្មីៗរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។
- **នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤** បានចាត់ចែងបុគ្គលិកឲ្យទៅចូលរួមវគ្គកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយស្តីអំពីរបាយការណ៍ស្ថានភាពស្ថេរភាពហិរញ្ញវត្ថុកម្ពុជាប្រចាំឆ្នាំ២០២៣ របស់ ធនាគារជាតិ នៃកម្ពុជា។
- **នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៤** ក៏បានចាត់ចែងបុគ្គលិកឲ្យបានទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពី របៀបដោះស្រាយបញ្ហាឥណទានឲ្យ មានប្រសិទ្ធភាព ជាមួយគ្រូឯកទេសនៅធនាគារអេស៊ីលីដា ។
- **នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៤** បានចាត់ចែងបុគ្គលិកឲ្យចូលរួមវគ្គបណ្តុះបណ្តាលលើសារាចរណែនាំស្តីពីការរៀបចំឥណទានឡើងវិញ។
- **នៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២៤** បានចាត់ចែងបុគ្គលិកឲ្យចូលរួមវគ្គសិក្ខាសាលាថ្នាក់តំបន់សម្រាប់ប្រធានសាខា ស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានហិរញ្ញវត្ថុ នៅក្នុងការធានានូវប្រសិទ្ធភាពនៃប្រតិបត្តិការប្រកបដោយចីរភាព ការទទួលខុសត្រូវ និងបរិយាបន្ន របស់សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា។
- **នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៤** បានចាត់ចែងបុគ្គលិកឲ្យចូលរួមវគ្គបណ្តុះបណ្តាលលើការប្រកាសស្តីពី អនុបាតសន្ទនីយភាព សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ របស់ធនាគារជាតិ នៃកម្ពុជា ។
- **នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២៤** អគ្គនាយក ក៏បានចូលរួមក្នុងសន្និសីទមីក្រូហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤ ស្តីពី និរន្តភាព និងបរិយាបន្នមីក្រូហិរញ្ញវត្ថុ បច្ចុប្បន្នភាព និងដំណើរវិវឌ្ឍន៍នៃវិស័យរបស់សមាគមធនាគារនៅកម្ពុជា និងធនាគារជាតិនៃកម្ពុជា។



# សមិទ្ធផល និងព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ(បន្ត)

## កម្មវិធីជំនួបបុគ្គលិកគ្រប់ជាន់ថ្នាក់និងធ្វើការចែកអាំងប៉ាវក្នុងឱកាសបុណ្យចូលឆ្នាំចិន







# សមិទ្ធផល និងព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ(បន្ត)

## ពិធីប្រគល់-ទទួលអំណោយ

ដោយមើលឃើញអំពីសារៈសំខាន់ នៃការផ្តល់ជូនទៅវិញដល់សហគមន៍ និងការទទួលខុសត្រូវមួយក្នុងសង្គមជាពិសេស ការចូលរួមជាមួយនឹងរាជរដ្ឋាភិបាល ហេតុនេះហើយ ឯកឧត្តម តាំង ផុងលី និង លោកជំទាវ សារុន វិធុរត្ន័ ព្រមទាំងក្រុមគ្រួសារ អមដំណើរដោយបុគ្គលិកទាំងអស់ តាំងនាមឲ្យស្ថាប័ន បានចូលរួមសកម្មភាពសង្គមមនុស្សធម៌យ៉ាងទូលំទូលាយជាមួយ សមាគមន៍ និងមូលនិធិនានា រួមទាំងទ័យទាន ថវិកាមួយចំនួន និងចង្ហាន់ប្រគេនជូនដល់ព្រះសង្ឃចំនួន៣៥០អង្គផងដែរ។









# ២

# ផលិតផល និងអតិថិជន

# ផលិតផល និងអតិថិជន

## ផលិតផល

### គោលការណ៍សង្ខេប

- ទំហំឥណទានផ្តល់ជូនតាមតម្រូវការ
- អត្រាការប្រាក់អាចចរចាបាន
- របៀបសងមានច្រើនប្រភេទតាមតម្រូវការ
- កម្ចីមានរយៈពេលវែង
- បុគ្គលិករួសរាយរាក់ទាក់ប្រកបដោយក្រមសីលធម៌ និងវិជ្ជាជីវៈ
- ឯកសារមានលក្ខណៈសាមញ្ញ និងងាយស្រួល
- សេវាកម្មរហ័ស និងគួរឲ្យទុកចិត្ត ។

### ឥណទានទាំងអស់ដែលស្ថាប័នផ្តល់ជូនរួមមាន

- ឥណទានទូទៅ
- ឥណទានឯកត្តជន
- ឥណទានក្រុម
- ឥណទានអាជីវកម្ម
- ឥណទានផ្ទាល់ខ្លួន
- ឥណទានសម្រាប់កសិកម្ម
- ឥណទានសម្រាប់ទិញយានយន្ត

### ទំនាក់ទំនងសម្រាប់ព័ត៌មានបន្ថែម តាមរយៈ

- 023 223 139 ( ការិយាល័យកណ្តាល )
- 011 999 627 ( សាខា កណ្តាលស្ទឹង )
- 011 999 587 ( សាខា តាខ្មៅ )
- Facebook: Anakut Microfinance Plc
- Email: info@anakutmfi.com.kh



# ផលិតផល និងអតិថិជន

## អតិថិជន ទិញលក់អង្ករ




នៅក្នុងប្រទេសកម្ពុជា មុខរបរទិញលក់អង្ករ គឺបានដើរតួយ៉ាងសំខាន់ជួយដល់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា តាមរយៈការទិញលក់នៅតាមទីផ្សារនានា ទីប្រជុំជន និងជាពិសេសនៅតាមសហគមន៍ជនបទផងដែរ ដើម្បីផ្គត់ផ្គង់តម្រូវការជាប្រចាំថ្ងៃរបស់ប្រជាជន ព្រមទាំងបានជួយលើកតម្កើននូវតម្លៃស្រូវអង្ករដែលជាផលិតផលនៅក្នុងស្រុក មិនតែប៉ុណ្ណោះមុខរបរទិញលក់អង្ករក៏បានផ្តល់ជាប្រាក់ចំណូលសមរម្យសម្រាប់ទ្រទ្រង់សេដ្ឋកិច្ចក្នុងគ្រួសារបានយ៉ាងល្អប្រសើរផងដែរ។

លោក **ម៉ាត់ វណ្ណា** និងលោកស្រី **យក់ ស្រីណា** បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាជាប្តីប្រពន្ធ ហើយពួកគាត់មានកូនចំនួន ០១នាក់។ ពួកគាត់រស់នៅ ភូមិ ទួលសាលា ឃុំ ស្អាងភ្នំ ស្រុក ស្អាង ខេត្ត កណ្តាល ។ ដោយមើលឃើញពីតម្រូវការប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋរស់នៅក្នុងភូមិ ឃុំ ស្រុក គាត់បានសម្រេចចិត្តប្រកបមុខរបរ ទិញលក់អង្ករនៅភូមិឃុំ ដែលគាត់រស់នៅអស់រយៈពេលជាង០៤ឆ្នាំមកហើយ។

មុខរបរទិញលក់អង្ករមួយនេះ បានដើរតួរយ៉ាងសំខាន់ក្នុងការរួមចំណែកលើកស្ទួយកម្រិតជីវភាពគ្រួសាររបស់គាត់ឱ្យកាន់តែប្រសើរឡើងជាលំដាប់។ អង្ករដែលគាត់យកមកលក់គឺមានច្រើនប្រភេទទៅតាមតម្រូវការរបស់អតិថិជន។ គាត់ និង ប្រពន្ធរបស់គាត់ធ្លាប់បានពិភាក្សាគ្នាចង់ពង្រីកមុខរបរមួយនេះបន្ថែមបន្តទៀត ដើម្បីទទួលបានប្រាក់ចំណូលច្រើនជាងមុន ប៉ុន្តែដោយសារគាត់ខ្វះដើមទុនទើបពួកគាត់សម្រេចចិត្តមិនបានពង្រីកមុខរបរមួយនេះអោយបានធំជាងមុនទេ។

ថ្ងៃមួយ មន្ត្រីឥណទានរបស់ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី** បានចុះផ្សព្វផ្សាយពីសេវាឥណទាននៅភូមិ ទួលសាលា ឃុំ ស្អាងភ្នំ ស្រុក ស្អាង ខេត្ត កណ្តាល គាត់ក៏បានពិភាក្សាជាមួយប្រពន្ធរបស់គាត់ ហើយក៏សម្រេចស្នើសុំប្រាក់កម្ចីពី **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី** ចាប់តាំងពីថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ដើម្បីពង្រីកមុខរបរមួយនេះ បន្ទាប់ពីទទួលបានប្រាក់កម្ចីនៅថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០២៤ គាត់ពង្រីកកន្លែងសម្រាប់ស្តុកអង្ករ និងទិញអង្ករមកស្តុកទុកសម្រាប់លក់កាន់តែច្រើនជាងមុនបន្ថែមទៀត។ ពីមួយថ្ងៃទៅមួយថ្ងៃ មុខរបររបស់គាត់មានការរីកចំរើន និងមានការគាំទ្រច្រើនពីប្រជាជនរស់នៅក្នុងតំបន់និងក្រៅតំបន់ ។ តាំងពីទទួលបានការគាំទ្រពីការផ្តល់ប្រាក់កម្ចីនៅ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី** លោក **ម៉ាត់ វណ្ណា** និងលោកស្រី **យក់ ស្រីណា** អាចបន្ថែមទុនទៅលើមុខរបរមួយនេះជាបន្តបន្ទាប់ និងទទួលបានប្រាក់ចំណូលច្រើនជាងមុន ដែលបានលើកស្ទួយជីវភាពគ្រួសារអោយល្អប្រសើរជាងមុន។

# ផលិតផល និងអតិថិជន

## អតិថិជន លក់កាហ្វេ និងភេសជ្ជៈគ្រប់មុខ



នៅក្នុងប្រទេសកម្ពុជា មុខរបរលក់ កាហ្វេ និងភេសជ្ជៈគ្រប់មុខ បានដើរតួយ៉ាងសំខាន់ក្នុងការជួយដល់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា និងជាពិសេសនៅតាមជនបទភូមិស្រុក និងបណ្តាខេត្តនានាផងដែរ ដើម្បីផ្គត់ផ្គង់បានជាតម្រូវការក្នុងភូមិស្រុកងាយស្រួលដោយមិនពិបាកធ្វើដំណើរទៅទិញឆ្ងាយនៅទីរួមស្រុកឺខេត្តផងដែរ និងបានផ្តល់ការកាត់បន្ថយចំណាយច្រើនដល់ប្រជាជនក្នុងភូមិស្រុក។ ហើយមុខរបរមួយនេះក៏ជាតម្រូវការចាំបាច់របស់ប្រជាជនមួយចំនួន និងមានទីផ្សារខ្ពស់ក្នុងជីវិតប្រចាំថ្ងៃរបស់អតិថិជនផងដែរ។

លោក **ញឹម ទូច** និងលោកស្រី **ល្អុត អឿន** ជាម្តាយនិងកូន ។ ពួកគាត់រស់នៅ ភូមិ វែង ឃុំ សឹង្ហ ស្រុក សំរោង ខេត្ត តាកែវ ។ ដោយមើលឃើញពីតម្រូវការប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋរស់នៅក្នុងភូមិ វែង គាត់បានប្រកបមុខរបរលក់ កាហ្វេ និងភេសជ្ជៈគ្រប់មុខ នៅផ្ទះរបស់គាត់ អស់រយៈពេលជាង០២ឆ្នាំមកហើយ។

មុខរបរលក់ កាហ្វេ និងភេសជ្ជៈគ្រប់មុខ មួយនេះ បានដើរតួរយ៉ាងសំខាន់ក្នុងការរួមចំណែកលើកស្ទួយជីវភាពគ្រួសាររបស់គាត់បានមួយកម្រិត។ មុខរបររបស់គាត់មួយនេះមានលក់ កាហ្វេ និងភេសជ្ជៈគ្រប់មុខ ផងដែរតាមតម្រូវការរបស់អតិថិជន។ គាត់ និងម្តាយរបស់គាត់ធ្លាប់បានពិភាក្សាគ្នាចង់អោយមុខរបរមួយនេះមានការរីកចម្រើន និងទទួលបានប្រាក់ចំនូលច្រើនជាងមុន តែដោយសារគាត់ខ្វះដើមទុន ទើបពួកគាត់មិនបានពង្រីកមុខរបរមួយនេះអោយបានល្អប្រសើរជាងមុនទេ។

ថ្ងៃមួយ មន្ត្រីឥណទានរបស់ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី** បានចុះផ្សព្វផ្សាយពីសេវាឥណទាននៅភូមិ វែង ឃុំ សឹង្ហ ស្រុក សំរោង ខេត្ត តាកែវ គាត់ក៏បានពិភាក្សាជាមួយម្តាយរបស់គាត់ ហើយក៏សម្រេចស្នើសុំប្រាក់កម្ចីពី **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី** ចាប់តាំងពីថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០២៤ ដើម្បីពង្រីកមុខរបរមួយនេះ ដោយគាត់បានពង្រីក ទិញ កាហ្វេ និងភេសជ្ជៈគ្រប់មុខ បន្ថែមទៀត។ ពីមួយថ្ងៃទៅមួយថ្ងៃ មុខរបររបស់គាត់ក៏មានការរីកចម្រើន និងមានការគាំទ្រជាច្រើនពីប្រជាជនរស់នៅក្នុងភូមិស្រុក ។ តាំងពីទទួលបានការគាំទ្រពីការផ្តល់ប្រាក់កម្ចីនៅ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី** លោក **ញឹម ទូច** និងលោកស្រី **ល្អុត អឿន** អាចបន្ថែមទុនទៅលើមុខរបរមួយនេះជាបន្តបន្ទាប់ និងទទួលបាននូវប្រាក់ចំណូលច្រើនជាងមុន ដែលបានលើកស្ទួយជីវភាពគ្រួសារអោយល្អប្រសើរជាងមុន។

# របាយការណ៍ហិរញ្ញវត្ថុ

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសូមដាក់ជូននូវរបាយការណ៍ ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី ហៅកាត់ថា (“ក្រុមហ៊ុន”) សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មឥណទាន និងសេវាកម្មហិរញ្ញវត្ថុទៅអតិថិជននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ពុំមានការផ្លាស់ប្តូរជាសារវន្តសម្រាប់សកម្មភាពចម្បងរបស់ក្រុមហ៊ុន ក្នុងអំឡុងការិយបរិច្ឆេទនេះទេ។

## លទ្ធផលនៃប្រតិបត្តិការ

| | ដុល្លារអាមេរិក | ពាន់រៀល |
|---|---|---|
| ខាតសម្រាប់ការិយបរិច្ឆេទ | ១.២២៩.៣៦៦ | ៥.០០៤.៧៤៩ |

## ភាគលាភ

ក្រុមប្រឹក្សាភិបាលពុំបានណែនាំឱ្យមានការទូទាត់ភាគលាភណាមួយសម្រាប់ការិយបរិច្ឆេទនេះទេ។

## ទុនបម្រុង និងសំវិធានធន

ក្នុងអំឡុងការិយបរិច្ឆេទបច្ចុប្បន្ននេះ មានការផ្ទេរចំនួន៥២៦.៣៧៤ដុល្លារអាមេរិក ពីទុនបម្រុងតាមច្បាប់ទៅ ចំណេញរក្សាទុក។

## បំណុលពិបាកទារ និងបំណុលជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ចំណូលពេញលេញ ជាមួយនិងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការលុបចោលបំណុលពិបាកទារ និងការធ្វើសំវិធានធនសម្រាប់បំណុលជាប់សង្ស័យត្រូវបានធ្វើឡើង ហើយមានការជឿជាក់ថាមិនមានបំណុលពិបាកទារ និងពុំមានភាពចាំបាច់ដើម្បីធ្វើសំវិធានធនសម្រាប់បំណុលជាប់សង្ស័យឡើយ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងបណ្តាលឱ្យមានភាពចាំបាច់ ដើម្បីលុបចោលបំណុលពិបាកទារ ឬធ្វើសំវិធានធនសម្រាប់បំណុលជាប់សង្ស័យ នៅក្នុងរបាយការណ៍ ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ចំណូលពេញលេញ ជាមួយនិងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មចរន្តដែលមិនមានតម្លៃស្មើនឹងតម្លៃទីផ្សារ នៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបានកាត់បន្ថយតម្លៃឱ្យនៅត្រឹមតម្លៃដែលរំពឹងទុកនឹងអាចលក់បានលើទីផ្សារ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងបណ្តាលឱ្យមានការភ័ន្តច្រឡំដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្ត នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

## វិធីសាស្ត្រកំណត់តម្លៃ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងអំពីហេតុការណ៍ណាមួយ ដែលបានកើតឡើង និងដែលអាចបណ្តាលឱ្យកើតមានការភ័ន្តច្រឡំ ឬមានភាពមិនត្រឹមត្រូវទៅដល់វិធីសាស្ត្រកំណត់តម្លៃ ដែលបានអនុវត្តកន្លងមកលើទ្រព្យសកម្ម និងបំណុលរបស់ក្រុមហ៊ុនឡើយ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមាន៖

(១) បន្ទុកណាមួយលើទ្រព្យសកម្មរបស់ក្រុមហ៊ុនដែលបានកើតឡើង ដោយសារតែការដាក់បញ្ចាំសម្រាប់ធានា បំណុលរបស់បុគ្គលណាម្នាក់ឡើយចាប់តាំង ពីចុងការិយបរិច្ឆេទនេះ ឬ

(២) បំណុលយថាហេតុណាមួយរបស់ក្រុមហ៊ុនដែលបានកើតឡើងចាប់តាំងពីចុងការិយបរិច្ឆេទនេះ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗ ដែលត្រូវបានទាមទារឱ្យសង ឬអាចត្រូវបានទាមទារឱ្យសង ក្នុងអំឡុងរយៈពេល ១២ខែ បន្ទាប់ពីចុងការិយបរិច្ឆេទនេះដែលនឹងអាចមានផលប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចសងបំណុលរបស់ខ្លួន នៅថ្ងៃកំណត់សងនោះទេ។

## ការផ្លាស់ប្តូរនៃហេតុការណ៍

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានជ្រាបដឹងអំពីហេតុការណ៍ណាមួយ ដែលមិនត្រូវបានវែកញែកក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលបណ្តាលឱ្យមានចំនួនទឹកប្រាក់ ដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានការភ័ន្តច្រឡំឡើយ។

## ប្រតិបត្តិការមិនប្រក្រតី

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ជាលទ្ធផលនៃប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន ក្នុងអំឡុងការិយបរិច្ឆេទនេះ មិនបានទទួលរងនូវឥទ្ធិពលធ្ងន់ធ្ងរ ដែលកើតចេញពីកត្តាផ្សេងៗ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ទាំងឡាយ ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះឡើយ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះ នៃចុងការិយបរិច្ឆេទ មកទល់នឹងថ្ងៃចេញរបាយការណ៍នេះ ពុំមានកត្តាប្រតិបត្តិការ ឬព្រឹត្តិការណ៍ដែលមានលក្ខណៈជាសារវន្ត ឬមិនប្រក្រតីណាមួយបានកើតឡើង ដែលអាចប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធផលអាជីវកម្មរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទ ដែលរបាយការណ៍ត្រូវបានធ្វើឡើងឡើយ។

## ដើមទុន

ក្រុមហ៊ុន ពុំបានបោះផ្សាយភាគហ៊ុនណាមួយ ក្នុងអំឡុងការិយបរិច្ឆេទនេះទេ។

ក្រុមហ៊ុនពុំមានកិច្ចសន្យាផ្តល់ភាគហ៊ុនមិនទាន់បោះផ្សាយ និងមិនមានភាគហ៊ុនក្រោមកិច្ចសន្យាផ្តល់សិទ្ធិជា ភាគហ៊ុនរបស់ក្រុមហ៊ុននាចុងការិយបរិច្ឆេទនេះទេ។

## សមាជិកក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលនៅបម្រើការចាប់តាំងពីកាលបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុចុងក្រោយរួមមាន៖

| | |
|---|---|
| លោកស្រី **សារុន វិធុរ័ត្ន** | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក **តាំង ផុងលី** | សមាជិកក្រុមប្រឹក្សាភិបាល |
| លោកស្រី **ហេង បូធីតា** | អភិបាលឯករាជ្យ |
| លោក **អ៊ឹត វិធូរ** | អភិបាលឯករាជ្យ |

លោក **មុយ ម៉ារ៉ា** (លាឈប់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៤)

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងអំឡុង និងចុងការិយបរិច្ឆេទនេះ ពុំមានការរៀបចំណាមួយ ដែលមានក្រុមហ៊ុនជាភាគីមួយ ក្នុងគោលបំណងជួយដល់ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយការទិញយកភាគហ៊ុន ឬលិខិត បំណុលពីក្រុមហ៊ុន ឬពីក្រុមហ៊ុនដទៃមួយទៀតឡើយ។

ចាប់តាំងពីចុងការិយបរិច្ឆេទកន្លងទៅ ក្រុមប្រឹក្សាភិបាលពុំបានទទួល ឬមានសិទ្ធិទទួលយកនូវអត្ថប្រយោជន៍ណាមួយតាមរយៈការចុះកិច្ចសន្យាដែលបានធ្វើឡើងដោយក្រុមហ៊ុន ឬដោយក្រុមហ៊ុនដែលពាក់ព័ន្ធណាមួយ ជាមួយនឹងក្រុមហ៊ុនដែល

ក្រុមប្រឹក្សាភិបាលជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនដែលក្រុមប្រឹក្សាភិបាលនោះមានអត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្តឡើយ លើកលែងតែផលប្រយោជន៍ណាមួយដែលអាចត្រូវបានគិតថាកើតឡើងដោយគុណសម្បត្តិនៃប្រតិបត្តិការទាំងនោះដូចដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ២៦ នៃរបាយការណ៍ហិរញ្ញវត្ថុ។

## ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានភារកិច្ចធ្វើការបញ្ជាក់អះអាងថា របាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំឡើងនេះ បានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ព្រមទាំងលទ្ធផលនៃប្រតិបត្តិ-ការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នេះ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលតម្រូវឱ្យ៖

(ក) អនុវត្តគោលនយោបាយគណនេយ្យសមស្របដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានសមហេតុផល ហើយបន្ទាប់មកធ្វើការអនុវត្តគោលនយោបាយទាំងនេះឱ្យបានជាប់លាប់

(ខ) អនុលោមតាមលក្ខខណ្ឌតម្រូវនៃការលាតត្រដាងព័ត៌មាននៃស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពធុនតូច និងមធ្យមហៅកាត់ថា (“ស.រ.ហ.អ.ក.ស.ធ.ត.ម”) និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ឬប្រសិនបើមានការប្រាសចាកណាមួយពីស្តង់ដាទាំងនេះ ក្នុងការបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថា ការប្រាសចាកទាំងនេះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឱ្យបានសមរម្យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(គ) រក្សាកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព

(ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយពឹងផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីមិនសមរម្យក្នុងការសន្មតថា ក្រុមហ៊ុននឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគតដែលអាចប៉ាន់ស្មានបាន និងក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលតម្រូវឱ្យ៖

(ង) ត្រួតពិនិត្យ និងដឹកនាំ ក្រុមហ៊ុនឱ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចចិត្តជាសារវន្ត ដែលប៉ះពាល់ទៅដល់ប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាសេចក្តីសម្រេចចិត្តនេះ និង/ឬ សេចក្តីណែនាំទាំងនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវជាក់លាក់ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលបានអះអាងថា ក្រុមហ៊ុនបានអនុវត្តទៅតាមរាល់តម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់ចាប់ពីទំព័រទី ៩ ដល់ ៣៧ ត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពធុនតូច និងមធ្យម និង គោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ហើយបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននា ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នេះ។

ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាល




**លោកស្រី សារុន វិធុរ័ត្ន**

ប្រធានក្រុមប្រឹក្សាភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥

# របាយការណ៍របស់សវនករឯករាជ្យ

## ជូនចំពោះភាគទុនិករបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី

### សេចក្តីរាយការណ៍សវនកម្មនៃរបាយការណ៍ហិរញ្ញវត្ថុ

#### មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី ដែលហៅកាត់ថា (“ក្រុមហ៊ុន”) ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី៣១ខែធ្នូឆ្នាំ២០២៤ព្រមទាំងរបាយការណ៍ចំណូលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នេះ និងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុផ្សេងៗ រួមទាំងព័ត៌មានគោលនយោបាយគណនេយ្យសារវន្ត ដែលបានបង្ហាញនៅទំព័រទី ៩ ដល់ ៣៧។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលមានការភ្ជាប់មកជាមួយនេះ ក៏បានបង្ហាញនូវទិដ្ឋភាពពិត និង ត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុ របស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងស្ថានភាពលំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នេះ ដោយអនុលោមស្របទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

#### មូលដ្ឋានក្នុងការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើនូវសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា( “ស.ស.អ.ក” )។ ទំនួលខុសត្រូវរបស់យើងខ្ញុំស្របតាមស្តង់ដានេះ ត្រូវបានពណ៌នាបន្ថែមក្នុងកថាខណ្ឌ ទំនួលខុសត្រូវរបស់សវនករឯករាជ្យលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានភាពគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិរបស់យើងខ្ញុំ។

#### ទំនួលខុសត្រូវឯករាជ្យភាព និងក្រមសីលធម៌

យើងខ្ញុំមានភាពឯករាជ្យពីក្រុមហ៊ុនដោយ ស្របតាមក្រមសីលធម៌អន្តរជាតិសម្រាប់គណនេយ្យករជំនាញ (រួមទាំងស្តង់ដាឯករាជ្យភាពអន្តរជាតិ) (“ក្រមសីលធម៌ IESBA”) របស់ក្រុមប្រឹក្សាស្តង់ដាសីលធម៌អន្តរជាតិ សម្រាប់គណនេយ្យករ រួមជាមួយនឹងតម្រូវការក្រមសីលធម៌ ដែលពាក់ព័ន្ធទៅនឹងសវនកម្មរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ហើយយើងបានបំពេញនូវទំនួលខុសត្រូវខាងសីលធម៌ផ្សេងទៀតរបស់យើង ដោយអនុលោមតាមតម្រូវការនៃ ក្រមសីលធម៌ទាំងនេះ និងក្រមសីលធម៌ IESBA។

#### ព័ត៌មានបន្ថែមក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកម្មខាងលើ

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន មានទំនួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗ រួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រួមជាមួយនិងរបាយការណ៍សវនកម្មខាងលើរបស់យើងខ្ញុំទេ។

មតិយោបល់របស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មិនរួមបញ្ចូលព័ត៌មានផ្សេងៗ ហើយយើងខ្ញុំមិនផ្តល់នូវទម្រង់សន្និដ្ឋានជាបែបធានាណាមួយឡើយ។

ទាក់ទងនឹងការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនយើងខ្ញុំមានទំនួលខុសត្រូវក្នុងការអាននូវព័ត៌មានផ្សេងៗ និងបានពិចារណាថា តើព័ត៌មានផ្សេងៗមានភាពមិនសមស្របជាសារវន្តជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឬក៏ចំណេះដឹងរបស់ខាងយើងខ្ញុំដែលទទួលបានពីសវនកម្ម ឬបើមិនដូច្នោះទេ លេចឡើងមានកំហុសឆ្គងជាសារវន្ត។

ផ្អែកលើកិច្ចការដែលយើងខ្ញុំបានអនុវត្ត ប្រសិនបើយើងខ្ញុំសន្និដ្ឋានមានកំហុសឆ្គងជាសារវន្តលើព័ត៌មានផ្សេងៗ យើងខ្ញុំតម្រូវឱ្យរាយការណ៍នូវហេតុការណ៍ទាំងនោះ។ យើងខ្ញុំពុំមានអ្វីដើម្បីរាយការណ៍ក្នុងករណីនេះទេ។

## ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលទៅលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលបានទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញនូវទិដ្ឋភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។ ក្រុមប្រឹក្សាភិបាលក៏ទទួលខុសត្រូវក្នុងការរក្សានូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងសំខាន់ៗដែលក្រុមប្រឹក្សាភិបាលកំណត់ថាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឱ្យជៀសផុតពីកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលជាអ្នកទទួលការខុសត្រូវក្នុងការវាយតម្លៃទៅលើ លទ្ធភាពបន្តប្រតិបត្តិការរបស់ក្រុមហ៊ុន ដោយឈរលើ មូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម ហើយធ្វើការលាតត្រដាងពិត ប្រសិនជាមាននូវកត្តាដែលពាក់ព័ន្ធនឹងនិរន្តរភាពនៃដំណើរការអាជីវកម្ម ហើយប្រើប្រាស់នូវមូលដ្ឋានគណនេយ្យបែបអនិរន្តរភាពលុះត្រាតែក្រុមប្រឹក្សាភិបាលមានបំណងរំលាយក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬមិនមានជម្រើសប្រាកដណាមួយប៉ុន្តែត្រូវតែធ្វើដូច្នេះ។

## ទំនួលខុសត្រូវរបស់សវនករឯករាជ្យលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺទទួលបានអំណះអំណាងយ៉ាងសមហេតុផលដែលថា តើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនពុំមានកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ និងចេញនូវរបាយការណ៍សវនកម្មដែលរួមមានមតិយោបល់របស់យើងខ្ញុំ។ អំណះអំណាងយ៉ាងសមហេតុផល គឺជាអំណះអំណាងកម្រិតខ្ពស់មួយប៉ុន្តែមិនបានធានាថាការធ្វើសវនកម្មដែលអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា តែងតែរកឃើញនូវកំហុសឆ្គងជាសារវន្តពេលដែលវាកើតមានឡើងនោះទេ។ កំហុសឆ្គងអាចកើតឡើងពីការក្លែងបន្លំ ឬការភ័ន្តច្រឡំត្រូវបានចាត់ទុកជាសារវន្ត ប្រសិនបើជាលក្ខណៈមួយៗ ឬជាលក្ខណៈរួមផ្តុំអាចមានឥទ្ធិពលលើការសម្រេចចិត្តសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់លើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដោយវិជ្ជាជីវៈ និងរក្សានូវការសង្ស័យដោយវិជ្ជាជីវៈនៅក្នុងសវនកម្មទាំងមូល។ យើងខ្ញុំក៏បាន៖

- កំណត់ និងវាយតម្លៃលើហានិភ័យកំហុសឆ្គងជាសារវន្តក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាតើវាបណ្តាល មកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ ហើយធ្វើការរៀបចំ និងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងទទួលបាននូវភស្តុតាងសវនកម្មដែលគ្រប់គ្រាន់ និងសមរម្យដើម្បីជាមូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ។ ហានិភ័យនៃការមិនបានរកឃើញនូវកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ គឺខ្ពស់ជាងហានិភ័យដែលបណ្តាលមកពីការភ័ន្តច្រឡំ ដោយសារតែការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិតគ្នា ការក្លែងបន្លំ ការលុបចោលដោយចេតនា ការបកស្រាយខុស ឬក៏ការបំពានលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់ពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធនឹងសវនកម្ម ដើម្បីរៀបចំនីតិវិធីសវនកម្មដែលសមស្របទៅតាមស្ថានភាព ប៉ុន្តែមិនមែនក្នុងគោលបំណងបញ្ចេញមតិយោបល់ពីប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុននោះឡើយ។
- វាយតម្លៃភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានអនុវត្ត និងភាពសមហេតុផលនៃប៉ាន់ស្មាន គណនេយ្យ និងលាតត្រដាងដែលពាក់ព័ន្ធដែលបានរៀបចំដោយក្រុមប្រឹក្សាភិបាល។

## ទំនួលខុសត្រូវរបស់សវនករឯករាជ្យលើការធ្វើ សវនកម្មរបាយការណ៍ហិរញ្ញវត្ថុ (ត)

- វាយតម្លៃទៅលើភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានអនុវត្ត និងភាពសមហេតុផលនៃប៉ាន់ស្មានគណនេយ្យ និងលាតត្រដាងដែលពាក់ព័ន្ធដែលបានរៀបចំដោយក្រុមប្រឹក្សាភិបាល។
- ធ្វើសេចក្តីសន្និដ្ឋានទៅលើភាពសមស្របនៃមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម ដែលប្រើប្រាស់ដោយគណៈគ្រប់គ្រង និងផ្អែកលើភស្តុតាងដែលទទួលបានថាតើមានភាពមិនប្រាកដប្រជាកើតឡើងជាសារវន្តដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចប៉ះពាល់ដល់លទ្ធភាពបន្តប្រតិបត្តិការរបស់ខ្លួនដោយឈរលើមូលដ្ឋាន និរន្តរភាពនៃដំណើរការអាជីវកម្ម។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា ភាពមិនប្រាកដប្រជាជាសារវន្តមួយកើតឡើង យើងខ្ញុំត្រូវបានតម្រូវឱ្យទាញនូវការយកចិត្តទុកដាក់ក្នុងរបាយការណ៍សវនកម្ម និងការលាតត្រដាងនានានៅក្នុង របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឬក៏កែប្រែមតិយោបល់របស់យើងខ្ញុំប្រសិនបើការកំណត់ទាំងនោះមិនគ្រប់គ្រាន់។ សេចក្តីសន្និដ្ឋានយើងខ្ញុំ គឺផ្អែកលើភស្តុតាងសវនកម្មដែលទទួលបាន រហូតដល់ថ្ងៃចេញរបាយការណ៍សវនកម្ម។ ទោះជាយ៉ាងណាព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចនឹងបង្កឱ្យក្រុមហ៊ុនបញ្ឈប់នូវនិរន្តរភាពនៃដំណើរការអាជីវកម្ម។
- វាយតម្លៃលើបទបង្ហាញរចនាសម្ព័ន្ធ និងមាតិកាទូទៅនៅក្នុង របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រួមទាំងការលាតត្រដាងបញ្ជាក់ថា តើរបាយការណ៍ហិរញ្ញវត្ថុក្រុមហ៊ុនតំណាងឱ្យប្រតិបត្តិការនិងព្រឹត្តិការណ៍ផ្សេងៗ ក្នុងរបៀបរបបមួយដែលសម្រេចបាននូវការបង្ហាញត្រឹមត្រូវ។

ក្នុងចំណោមចំណុចពាក់ព័ន្ធផ្សេងៗទៀត យើងខ្ញុំធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាភិបាលអំពីផែនការវិសាលភាពការងារ និងពេលវេលានៃសវនកម្ម និងចំណុចសំខាន់ៗដែលបានរកឃើញ និងរួមមានកង្វះខាតសំខាន់ៗនៅក្នុងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលយើងខ្ញុំបានរកឃើញនៅក្នុងអំឡុងសវនកម្មរបស់យើងខ្ញុំ។

### បញ្ហាដទៃ

របាយការណ៍នេះត្រូវបានធ្វើឡើងជូនចំពោះតែភាគទុនិករបស់ក្រុមហ៊ុនប៉ុណ្ណោះ។ យើងខ្ញុំមិនទទួលខុសត្រូវចំពោះបុគ្គលដទៃណាម្នាក់ចំពោះខ្លឹមសារនៃរបាយការណ៍នេះទេ។

ប៊ី ឌី អូ (ខេមបូឌា) លីមីធីត

រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

| | កំណត់ | ២០២៤ | | ២០២៣ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៦ | ៥.៨៨០ | ២៣.៦៦៧ | ៤.៩៩០ | ២០.៣៨៤ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | ៧ | ១៥៥.១១៥ | ៦២៤.៣៣៨ | ១៥៣.០៣៩ | ៦២៥.១៦៤ |
| សមតុល្យនៅធនាគារផ្សេងៗ | ៨ | ៨៨.២២៣ | ៣៥៥.០៩៨ | ១៣៣.៧២១ | ៥៤៦.២៥០ |
| ឥណទានទៅអតិថិជន | ៩ | ៣.៤៦១.៥៣៤ | ១៣.៩៣២.៦៧៤ | ៤.៦៨៤.១៩៨ | ១៩.១៣៤.៩៤៩ |
| គណនីត្រូវទទួលផ្សេងៗ | ១០ | ៥៧.៨៧២ | ២៣២.៩៣៤ | ៤៨.៣១៦ | ១៩៧.៣៧១ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ១១ | ១៩.៣០៤ | ៧៧.៦៩៨ | ៣១.២៣៧ | ១២៧.៦០៣ |
| ទ្រព្យអរូបី | ១២ | ២.៩៤៩ | ១១.៨៧០ | ៤.២៤៥ | ១៧.៣៤១ |
| **ទ្រព្យសកម្មសរុប** | | ៣.៧៩០.៨៧៧ | ១៥.២៥៨.២៧៩ | ៥.០៥៩.៧៤៦ | ២០.៦៦៩.០៦២ |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់កម្ចី | ១៣ | ២.៣១៩.៨១១ | ៩.៣៣៧.២៣៩ | ២.៣៤៥.៧៦៦ | ៩.៥៨២.៤៥៤ |
| គណនីត្រូវបង់ផ្សេងៗ | ១៤ | ៣០.០១៣ | ១២០.៨០២ | ២៩.៧៨២ | ១២១.៦៥៩ |
| បំណុលពន្ធចរន្ត | | ១៧៣ | ៦៩៦ | ១៧៣ | ៧០៧ |
| បំណុលពន្ធពន្យារ | ១៥ | - | - | ១៣.៧៧៩ | ៥៦.២៨៧ |
| **បំណុលសរុប** | | ២.៣៤៩.៩៩៧ | ៩.៤៥៨.៧៣៧ | ២.៣៨៩.៥០០ | ៩.៧៦១.១០៧ |
| **មូលធន** | | | | | |
| ដើមទុន | ១៦ | ៣.០០០.០០០ | ១២.០០០.០០០ | ៣.០០០.០០០ | ១២.០០០.០០០ |
| ទុនបម្រុងតាមច្បាប់ | ១៧ | ២៦.៤០៦ | ១០៦.២៨៤ | ៥៥២.៧៨០ | ២.២៥៨.១០៦ |
| ខាតបង្គរ | | (១.៥៨៥.៥២៦) | (៦.៤៦០.០៨៧) | (៨៨២.៥៣៤) | (៣.៦០៧.១៦០) |
| លម្អៀងនៃការបកប្រែរូបិយប័ណ្ណ | | - | ១៥៣.៣៤៥ | - | ២៥៧.០០៩ |
| **មូលធនសរុប** | | ១.៤៤០.៨៨០ | ៥.៧៩៩.៥៤២ | ២.៦៧០.២៤៦ | ១០.៩០៧.៩៥៥ |
| **បំណុល និងមូលធនសរុប** | | ៣.៧៩០.៨៧៧ | ១៥.២៥៨.២៧៩ | ៥.០៥៩.៧៤៦ | ២០.៦៦៩.០៦២ |

# របាយការណ៍ចំណូលពេញលេញ

## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

| | កំណត់ | ២០២៤ | | ២០២៣ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលការប្រាក់ | ១៨ | ៧៤២.៥១០ | ៣.០២២.៧៥៨ | ៨២៥.០០៨ | ៣.៣៩០.៧៨៣ |
| ចំណាយការប្រាក់ | ១៩ | (២២៨.៩២៥) | (៩៣១.៩៥៤) | (២២៦.៩១០) | (៩៣២.६००) |
| **ចំណូលការប្រាក់សុទ្ធ** | | ៥១៣.៥៨៥ | ២.០៩០.៨០៤ | ៥៩៨.០៩៨ | ២.៤៥៨.១៨៣ |
| សំវិធានធនសម្រាប់ឥណទានជាប់សង្ស័យ | ៩ | (១.១៤១.២៧៦) | (៤.៦៤៦.១៣៥) | (២៦៩.២៥៨) | (១.១០៦.៦៥០) |
| ចំណូលប្រតិបត្តិការផ្សេងៗ | ២០ | ៥៤.៥១៥ | ២២១.៩៣១ | ៦១.៧៦៩ | ២៥៣.៨៧១ |
| ចំណាយបុគ្គលិក | ២១ | (៤៦២.៩៦១) | (១.៨៨៤.៧១៤) | (៤៤១.០៤៣) | (១.៨១២.៦៨៧) |
| ចំណាយរំលស់ | ២២ | (១៣.៤២១) | (៥៤.៦៣៧) | (១៤.៤៦១) | (៥៩.៤៣៥) |
| ចំណាយទូទៅ និងរដ្ឋបាល | ២៣ | (១៨៦.៣៥១) | (៧៥៨.៦៣៥) | (២០៩.៤៧២) | (៨៦០.៩៣០) |
| **(ខាត)/ចំណេញមុនបង់ពន្ធ** | | (១.២៣៥.៩០៩) | (៥.០៣១.៣៨៦) | (២៧៤.៣៦៧) | (១.១២៧.៦៤៨) |
| ចំណាយពន្ធ | ២៤ | ៦.៥៤៣ | ២៦.៦៣៧ | ៣៣.៦៨២ | ១៣៨.៤៣៣ |
| **ខាតក្នុងការិយបរិច្ឆេទ** | | (១.២២៩.៣៦៦) | (៥.០០៤.៧៤៩) | (២៤០.៦៨៥) | (៩៨៩.២១៥) |
| (ខាត)/ចំណូលលម្អិតផ្សេងៗសុទ្ធនៃពន្ធ | | | | | |
| ខ្ទង់គណនីដែលបានបែងចែកឡើងវិញលើចំណេញ ឬខាត៖ | | | | | |
| - ការបកប្រែរូបិយប័ណ្ណបរទេស | | - | (១០៣.៦៦៤) | - | (៨៧.១៣៣) |
| **(ខាត)/ចំណូលលម្អិតសរុបក្នុងការិយបរិច្ឆេទ** | | (១.២២៩.៣៦៦) | (៥.១០៨.៤១៣) | (២៤០.៦៨៥) | (១.០៧៦.៣៤៨) |

# របាយការណ៍បម្រែបម្រួលមូលធន

## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

| | ដើមទុន | | ទុនបម្រុងតាមច្បាប់ | | ខាតបង្គរ | | លម្អៀងនៃការបកប្រែរូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣** | ៣.០០០.០០០ | ១២.០០០.០០០ | ៣៣០.១៧១ | ១.៣៥៩.៣១៤ | (៤១៩.២៤០) | (១.៧១៩.១៥៣) | - | ៣៤៤.១៤២ | ២.៩១០.៩៣១ | ១១.៩៨៤.៣០៣ |
| ខាតក្នុងការិយបរិច្ឆេទ | - | - | - | - | (២៤០.៦៨៥) | (៩៨៩.២១៥) | - | - | (២៤០.៦៨៥) | (៩៨៩.២១៥) |
| ខាតពេញលេញផ្សេងៗសុទ្ធនៃពន្ធ | - | - | - | - | - | - | - | (៨៧.១៣៣) | - | (៨៧.១៣៣) |
| **ខាតពេញលេញសរុប** | - | - | - | - | (២៤០.៦៨៥) | (៩៨៩.២១៥) | - | (៨៧.១៣៣) | (២៤០.៦៨៥) | (១.០៧៦.៣៤៨) |
| ***ប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុន*** | | | | | | | | | | |
| ការផ្ទេរទៅទុនបម្រុងតាមច្បាប់ តំណាងឱ្យប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុនសរុប | - | - | ២២២.៦០៩ | ៨៩៨.៧៩២ | (២២២.៦០៩) | (៨៩៨.៧៩២) | - | - | - | - |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | ៣.០០០.០០០ | ១២.០០០.០០០ | ៥៥២.៧៨០ | ២.២៥៨.១០៦ | (៨៨២.៥៣៤) | (៣.៦០៧.១៦០) | - | ២៥៧.០០៩ | ២.៦៧០.២៤៦ | ១០.៩០៧.៩៥៥ |
| ខាតក្នុងការិយបរិច្ឆេទ | - | - | - | - | (១.២២៩.៣៦៦) | (៥.០០៤.៧៤៩) | - | - | (១.២២៩.៣៦៦) | (៥.០០៤.៧៤៩) |
| ខាតពេញលេញផ្សេងៗសុទ្ធនៃពន្ធ | - | - | - | - | - | - | - | (១០៣.៦៦៤) | - | (១០៣.៦៦៤) |
| **ខាតពេញលេញសរុប** | - | - | - | - | (១.២២៩.៣៦៦) | (៥.០០៤.៧៤៩) | - | (១០៣.៦៦៤) | (១.២២៩.៣៦៦) | (៥.១០៨.៤១៣) |
| ***ប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុន*** | | | | | | | | | | |
| ការផ្ទេរទៅទុនបម្រុងតាមច្បាប់ តំណាងឱ្យប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុនសរុប | - | - | (៥២៦.៣៧៤) | (២.១៥១.៨២២) | ៥២៦.៣៧៤ | ២.១៥១.៨២២ | - | - | - | - |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | ៣.០០០.០០០ | ១២.០០០.០០០ | ២៦.៤០៦ | ១០៦.២៨៤ | (១.៥៨៥.៥២៦) | (៦.៤៦០.០៨៧) | - | ១៥៣.៣៤៥ | ១.៤៤០.៨៨០ | ៥.៧៩៩.៥៤២ |

# របាយការណ៍លំហូរសាច់ប្រាក់

## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

| | កំណត់ | ២០២៤ | | ២០២៣ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ខាតមុនបង់ពន្ធ | | (១.២៣៥.៩០៩) | (៥.០៣១.៣៨៦) | (២៧៤.៣៦៧) | (១.១២៧.៦៤៨) |
| និយ័តកម្ម៖ | | | | | |
| សំវិធានធនសម្រាប់ឥណទានជាប់សង្ស័យ | ៩ | ១.១៤១.២៧៦ | ៤.៦៤៦.១៣៥ | ២៦៩.២៥៨ | ១.១០៦.៦៥០ |
| រំលស់ទ្រព្យសកម្មអរូបី | ១២ | ១.២៩៦ | ៥.២៧៦ | ១.២៩២ | ៥.៣១០ |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ | ១១ | ១២.១២៦ | ៤៩.៣៦៥ | ១៣.១៦៩ | ៥៤.១២៥ |
| ចំណាយការប្រាក់ | ១៨ | ២២៨.៩២៥ | ៩៣១.៩៥៤ | ២២៦.៩១០ | ៩៣២.៦០០ |
| ចំណូលប្រតិបត្តិការមុនបម្រែបម្រួលដើមទុនបង្វិល | | ១៤៧.៧១៤ | ៦០១.៣៤៤ | ២៣៦.២៦២ | ៩៧១.០៣៧ |
| **បម្រែបម្រួលដើមទុនបង្វិល** | | | | | |
| ឥណទានទៅអតិថិជន | | ៨១.៣៨៨ | ៣២៧.៥៨៧ | ២៦២.៩០៣ | ១.០៧៣.៩៥៩ |
| គណនីត្រូវទទួលផ្សេងៗ | | (៩.៥៥៦) | (៣៨.៤៦៣) | ១១.៨០៧ | ៤៨.២៣២ |
| គណនីត្រូវបង់ផ្សេងៗ | | (៦៥៦) | (២.៦៤០) | ១.៩៦១ | ៨.០១១ |
| សាច់ប្រាក់បានមកពីប្រតិបត្តិការ | | ២១៨.៨៩០ | ៨៨៧.៨២៨ | ៥១២.៩៣៣ | ២.១០១.២៣៩ |
| ពន្ធលើប្រាក់ចំណេញបានបង់ | | (៧.២៣៦) | (២៩.៤៥៨) | (៧.៩៣៧) | (៣២.៦២១) |
| ការប្រាក់ដែលបានបង់ | | (២២៨.០៣៨) | (៩២៨.៣៤៣) | (២២៨.០៤៩) | (៩៣៧.២៨១) |
| សាច់ប្រាក់សុទ្ធ(ប្រើក្នុង)/បានមកពីសកម្មភាពប្រតិបត្តិការ | | (១៦.៣៨៤) | (៦៩.៩៧៣) | ២៧៦.៩៤៧ | ១.១៣១.៣៣៧ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ តំណាងឱ្យសាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ | ១១ | (១៩៣) | (៧៨៦) | (៥.៥១៩) | (២២.៦៨៣) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| ការទូទាត់សងប្រាក់កម្ចី តំណាងឱ្យសាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពហិរញ្ញប្បទាន | | (២៥.៩៥៥) | (១០៥.៦៦៣) | (៣៩០.០០៤) | (១.៦០២.៩១៦) |

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ (ត)

| | កំណត់ | ២០២៤ | | ២០២៣ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **តំហយសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | (៤២.៥៣២) | (១៧៦.៤២២) | (១១៨.៥៧៦) | (៤៩៤.២៦២) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើមការិយបរិច្ឆេទ** | | ១៤១.៧៥០ | ៥៧៩.០៤៨ | ២៦០.៣២៦ | ១.០៧១.៧៦២ |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | | - | (៣.២៧៣) | - | ១.៥៤៨ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅចុងការិយបរិច្ឆេទ** | | ៩៩.២១៨ | ៣៩៩.៣៥៣ | ១៤១.៧៥០ | ៥៧៩.០៤៨ |

## សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន៖

| | កំណត់ | ២០២៤ | | ២០២៣ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| សាច់ប្រាក់ក្នុងដៃ | ៦ | ៥.៨៨០ | ២៣.៦៦៧ | ៤.៩៩០ | ២០.៣៨៤ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា (មិនរួមបញ្ចូលប្រាក់តម្កល់តាមច្បាប់) | ៧ | ៥.១១៥ | ២០.៥៨៨ | ៣.០៣៩ | ១២.៤១៤ |
| សមតុល្យនៅធនាគារផ្សេងៗ | ៨ | ៨៨.២២៣ | ៣៥៥.០៩៨ | ១៣៣.៧២១ | ៥៤៦.២៥០ |
| | | ៩៩.២១៨ | ៣៩៩.៣៥៣ | ១៤១.៧៥០ | ៥៧៩.០៤៨ |

# អាសយដ្ឋានទាក់ទង

# ទីស្នាក់ការកណ្ដាល និងសាខា










## ការិយាល័យកណ្ដាល

ផ្ទះលេខ២៤៥ មហាវិថីព្រះមុនីវង្ស
សង្កាត់អូរឬស្សី៤ ខណ្ឌ៧មករា
រាជធានីភ្នំពេញ

## សាខាកណ្ដាលស្ទឹង

ផ្លូវជាតិលេខ២ ភូមិប្រឡាយ
ឃុំបឹងខ្យាង ស្រុកកណ្ដាលស្ទឹង
ខេត្តកណ្ដាល

## សាខាតាខ្មៅ

ផ្លូវលេខ ១១៥ ភូមិខ្ពបវែង
សង្កាត់កំពង់សំណាញ់
ក្រុងតាខ្មៅ ខេត្តកណ្ដាល

**Phnom Penh(Head Office)**
Home N°245,Preah Monivong Blvd
Sankat Orussey 4, Khan 7 Makara,
Phnom Penh.
☎ ( 855 ) 23 223 139

**Kandal Steung Branch**
Nationl Road 2, Beung Khchang
Commune,Kandal Stueng District,
Kandal Province.
☎ ( 855 ) 11 999 627

**Takmao Branch**
St.N°115,Phum Khpob Veng,Sangkat
Kampong Samnah,Krong Ta Khmau,
Kandal Province
☎ ( 855 ) 11 999 587

ទូរស័ព្ទ : (+៨៥៥) ២៣ ២២៣ ១៣៩
អ៊ីមែល : info@anakutmfi.com.kh
គេហទំព័រ : www.anakutmfi.com.kh
ទំព័រហ្វេសបុក : Anakut Microfinance

# ដៃគូសហការ

Cambodia Microfinance Association

National Social Security Fund (NSSF)

CBC

ធនាគារ វឌ្ឍនៈ Vattanac Bank

អេស៊ីលីដា ACLEDA BANK

ធនាគារកម្ពុជាសាធារណៈ CAMBODIAN PUBLIC BANK 東埔寨大眾銀行

BIDC Bank — BANK FOR INVESTMENT AND DEVELOPMENT OF CAMBODIA PLC.

ABA BANK — NATIONAL BANK OF CANADA GROUP

PRINCE BANK

ក្រុមហ៊ុន ធី ជី ស៊ី ខេមបូឌា ឯ.ក
TGC Cambodia Co., LTD

Wing

លីហួរ វេរលុយ

IDEALINK CONSULTING

CFOCN

ONLINE — IN TOUCH WITH YOUR WORLD

cellcard

# កំណត់សម្គាល់




២០២៤

## របាយការណ៍ប្រចាំឆ្នាំរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អនាគត ភីអិលស៊ី

# ៨ឆ្នាំកន្លងមក




២០១៧




២០១៨




២០១៩




២០២០




២០២១




២០២២




២០២៣

អនាគត
ANAKUT

ជោគជ័យជាមួយគ្នា For Better Tomorrow

(+៨៥៥) ២៣ ២២៣ ១៣៩

info@anakutmfi.com.kh

www.anakutmfi.com.kh

Anakut Microfinance